រាជរដ្ឋាភិបាលកម្ពុជា

# សៀវភៅណែនាំសម្រាប់អ្នកចូលរួម
# ស្តីពី
# ការដាក់បញ្ចូលពិការភាព
# នៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ



បោះពុម្ពលើកទី២ ខែមិថុនា ឆ្នាំ២០១៧

unicef

Australian Aid

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ នៅថ្ងៃទី ០១ ខែតុលា ឆ្នាំ២០០៧ និងបានផ្តល់សច្ចាប័នដល់អនុសញ្ញានេះ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២។ ព្រះរាជាណាចក្រកម្ពុជាបានប្រកាសដាក់ឲ្យប្រើប្រាស់ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ក្នុងគោលបំណងការពារសិទ្ធិ និងសេរីភាពរបស់ជនពិការ ការពារផលប្រយោជន៍ជនពិការ ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនពិការ និងស្តារកាយសម្បទាសតិបញ្ញា និងវិជ្ជាជីវៈ ដើម្បីធានាលទ្ធភាពក្នុងការចូលរួមដ៏ពេញលេញ និងដោយស្មើភាពគ្នានៃជនពិការក្នុងសកម្មភាពនានារបស់សង្គម។

ក្រសួងមហាផ្ទៃ គឺជាតួអង្គមួយដ៏សំខាន់ក្នុងការរួមចំណែកអនុវត្តអនុសញ្ញា និងច្បាប់ខាងលើឲ្យមានប្រសិទ្ធភាព។ ក្រសួងបាន និងកំពុងយកចិត្តទុកដាក់អនុវត្តនូវវិធានការ និងសកម្មភាពការងារ ដើម្បីដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ច និងការអភិវឌ្ឍ។ វិធានការ និងសកម្មភាពការងារទាំងនោះ រួមមាន ការរៀបចំក្រុមការងារ ក្រុមគ្រូបង្គោល លិខិតបទដ្ឋានគតិយុត្ត សៀវភៅណែនាំសម្រាប់គ្រូបង្គោល និងអ្នកចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងសហការជាមួយក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិលនានាដែលពាក់ព័ន្ធ។

សៀវភៅណែនាំសម្រាប់អ្នកចូលរួមស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើងយ៉ាងម៉ត់ចត់តាមរយៈ ការចុះស្រាវជ្រាវ ការប្រជុំពិភាក្សាពិគ្រោះយោបល់ ការបណ្តុះបណ្តាលសាកល្បង និងការកែសម្រួលជាច្រើនដំណាក់កាល។ ធាតុចូលសំខាន់ៗនៃសៀវភៅនេះ គឺបានមកពីលិខិតបទដ្ឋានគតិយុត្ត ឯកសារបច្ចេកទេស និងបទពិសោធន៍នានាក្នុងកម្រិតជាតិ និងពិភពលោក។

សៀវភៅណែនាំនេះត្រូវបានតាក់តែងឡើងសម្រាប់សិក្ខាកាមមកពីរដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ប្រើប្រាស់ជាឯកសារជំនួយស្មារតីក្នុងការអភិវឌ្ឍចំណេះដឹងជាមូលដ្ឋានអំពីពិការភាព និងធានាឲ្យមានការចូលរួមយ៉ាងសកម្មពីជនពិការ ដើម្បីបង្កើតបរិស្ថានដែលគ្មានឧបសគ្គរាំងដល់ជនពិការ ព្រមទាំងពិចារណាដោយយកចិត្តទុកដាក់ក្នុងការបញ្ចូលពិការភាពទៅក្នុងដំណើរការកសាងផែនការរបស់ខ្លួននីមួយៗ។ សៀវភៅណែនាំនេះ បានផ្តល់នូវសារសំខាន់ៗមួយចំនួនសម្រាប់សិក្ខាកាម និងអ្នកពាក់ព័ន្ធផ្សេងៗទៀត រួមមាន "*ពុំមានអ្វីសម្រាប់ជនពិការ ដោយគ្មានការចូលរួមពីជនពិការឡើយ*" "*ការផាត់ចេញជនពិការនឹងធ្វើឲ្យជនពិការក្លាយជាបញ្ហានៃគ្រួសារ និងសង្គម ផ្ទុយទៅវិញ បើបានដាក់បញ្ចូលជនពិការ នោះជនពិការនឹងក្លាយជាតួអង្គដ៏សំខាន់ក្នុងការរួមចំណែកអភិវឌ្ឍន៍គ្រួសារ និងសង្គម*" និង "*មើលសមត្ថភាពរបស់មនុស្សជាជាងមើលពីពិការភាពរបស់មនុស្ស*"។

ក្រសួងមហាផ្ទៃ សង្ឃឹមយ៉ាងមុតមាំថា សៀវភៅណែនាំសម្រាប់អ្នកចូលរួមនេះនឹងក្លាយជាឧបករណ៍ដ៏សំខាន់ សម្រាប់ដាក់បញ្ចូលបញ្ហាពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សា មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាឲ្យមានប្រសិទ្ធភាព។

ក្នុងនាមក្រសួងមហាផ្ទៃ ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះក្រុមការងារបច្ចេកទេស ទីប្រឹក្សា និងអ្នកពាក់ព័ន្ធនានា ដែលបានខិតខំប្រឹងប្រែងក្នុងការតាក់តែងសៀវភៅណែនាំសម្រាប់អ្នកចូលរួមដ៏មានសារៈសំខាន់។ ទន្ទឹមនេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះ អង្គការយូនីសេហ្វ និងរដ្ឋាភិបាលអូស្ត្រាលី ដែលបានរួមចំណែកក្នុងការផ្តល់នូវការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាដល់ដំណើរការតាក់តែងសៀវភៅណែនាំសម្រាប់អ្នកចូលរួម។

ក្រសួងមហាផ្ទៃ សូមស្វាគមន៍រាល់ព័ត៌មានត្រលប់ ឬមតិយោបល់កែលម្អពីបណ្តាអ្នកអនុវត្តផ្ទាល់ និងអ្នកពាក់ព័ន្ធនានា ដើម្បីធ្វើឲ្យសៀវភៅណែនាំសម្រាប់អ្នកចូលរួមស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិនេះកាន់តែមានភាពប្រសើរឡើង។

រាជធានីភ្នំពេញ ថ្ងៃទី..... ខែ..... ឆ្នាំ២០១៦

**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**

**និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

សក់ សេដ្ឋា

# មាតិកា


សេចក្តីផ្តើម.......................................................................................................................១

ជំពូកទី១ ៖ ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល ............................................................................៤

ជំពូកទី២ ៖ ចំណេះដឹងជាមូលដ្ឋានអំពីពិការភាព និងការដាក់បញ្ចូលពិការភាព ..............................៥

ជំពូកទី៣ ៖ ការបង្ហាញពីការគោរព និងសេចក្តីថ្លៃថ្នូរ.................................................................២៦

ជំពូកទី៤ ៖ ការប្រាស្រ័យទាក់ទងជាមួយជនពិការ .................................................................៣៣

ជំពូកទី៥ ៖ ការបង្កើតបរិស្ថានដែលគ្មានឧបសគ្គរាំងដល់ជនពិការ...........................................៣៩

ជំពូកទី៦ ៖ ការជានាឱ្យមានការចូលរួមយ៉ាងសកម្ម ...............................................................៤៨

ជំពូកទី៧ ៖ ការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការកសាងផែនការ......................................៥៣

ជំពូកទី៨ ៖ ការវាយតម្លៃវគ្គបណ្តុះបណ្តាល និងបញ្ជីអង្គការសង្គមស៊ីវិលដែលធ្វើការងារពិការភាព ...៦០

# ១. សេចក្តីផ្តើម

វគ្គបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ រៀបចំឡើងសម្រាប់សិក្ខាកាមកម្រិតក្រុង ស្រុក ខណ្ឌ រួមមាន ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល ប្រធានការិយាល័យ ប្រធានអង្គភាព មន្ត្រីសំខាន់ៗ ទីប្រឹក្សាក្រុង ស្រុក និងមន្ត្រីការិយាល័យសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ។

សៀវភៅណែនាំសម្រាប់អ្នកចូលរួម ស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌមាន៨ជំពូក រួមមាន ការចាប់ផ្តើមវគ្គ ចំណេះដឹងជាមូលដ្ឋានអំពីពិការភាព ការបង្ហាញពីការគោរពនិងសេចក្តីថ្លៃថ្នូរ ការប្រាស្រ័យទាក់ទងជាមួយជនពិការ ការបង្កើតបរិស្ថានដែលគ្មានឧបសគ្គរាំងដល់ជនពិការ ការធានាឱ្យមានការចូលរួមឱ្យបានសកម្ម ការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការកសាងផែនការ និងការវាយតម្លៃវគ្គនិងបញ្ជីអង្គការសង្គមស៊ីវិលដែលធ្វើការងារពិការភាព។ គ្រប់ជំពូកទាំងអស់ក្នុងសៀវភៅនេះ ត្រូវគ្នានឹងលំហូរនៃជំពូកនីមួយៗរបស់សៀវភៅណែនាំសម្រាប់គ្រូបណ្តុះបណ្តាល។ បន្ទាប់ពីជំពូកនីមួយៗមានប្រអប់មួយសម្រាប់សិក្ខាកាមអាចសរសេរកំណត់សម្គាល់របស់ខ្លួនបាន។ ឧទាហរណ៍ ៖ តើអ្នកបានរៀនអ្វីខ្លះ? តើមានអ្វីថ្មីសម្រាប់អ្នក? តើអ្នកនឹងយកអ្វីខ្លះទៅអនុវត្ត?

## ១.១. មូលហេតុនៃការរៀបចំសៀវភៅណែនាំនេះ

ក្នុងចំណោមប្រជាជនទាំងអស់នៅលើពិភពលោកមានពិការភាព១៥% (ក្នុងចំណោមមនុស្ស៧នាក់មាន១នាក់មានពិការភាព)។ ជារឿយៗពួកគាត់ត្រូវបានរាំងឬផាត់ចេញ មិនអាចចូលរួមក្នុងសង្គមបាន ទោះបីជាមានសិទ្ធិដូចគ្នានឹងមនុស្សផ្សេងទៀត ដូចជា សិទ្ធិទទួលបានការអប់រំ មានការងារធ្វើ រៀបអាពាហ៍ពិពាហ៍ និងចូលរួមនៅក្នុងសហគមន៍ជាដើម។ រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកដឹកនាំសហគមន៍ត្រូវធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានសេវា និងព័ត៌មាន។

រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចធ្វើការងារ ដើម្បីឱ្យមានសមភាពសម្រាប់ប្រជាពលរដ្ឋនៅក្នុងប្រទេសរបស់ខ្លួនរួមទាំងជនពិការ។ ចំណុចនេះត្រូវបានបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ ទន្ទឹមគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាកំពុងស្ថិតនៅក្នុងដំណើរការផ្ទេរមុខងារ និងធនធានមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការផ្ទេរមុខងារ និងធនធានទាំងនេះមានន័យថា បន្ថែមការទទួលខុសត្រូវ និងសិទ្ធិអំណាចធ្វើសេចក្តីសម្រេចចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូច្នេះរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល។

ក្រុង ស្រុក ខណ្ឌ គឺជានីតិបុគ្គលសាធារណៈ ដែលសមាជិកក្រុមប្រឹក្សារបស់ខ្លួនកើតចេញពីការបោះឆ្នោតអសកល។ ដូច្នេះ ក្រុង ស្រុក ខណ្ឌត្រូវមាន គណនេយ្យភាព និងការឆ្លើយតបចំពោះបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋគ្រប់រូបក្នុងសហគមន៍របស់ខ្លួន ជាពិសេសជនងាយរងគ្រោះ។ ផែនការអនុវត្ត

រយៈពេល៣ឆ្នាំ(ផអ៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផ្តោតជាសំខាន់លើបរិយាប័ន្ន[1] និងសមធម៌សង្គម ក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចល្អដែលកំពុងបានផ្តល់ឱកាសឱ្យជនពិការបានចូលរួមក្នុងដំណើរការអភិវឌ្ឍ។ អ្នកចូលរួមក្នុងការបណ្តុះបណ្តាលរួមទាំងជនពិការនឹងរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការប្តេជ្ញាចិត្ត ធ្វើឱ្យប្រសើរឡើងនូវវប្បធម៌ប្រជាធិបតេយ្យដោយមានការចូលរួមនៅមូលដ្ឋាន គណនេយ្យភាពចំពោះប្រជាពលរដ្ឋ សេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធនាំមកនូវការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចដើម្បីឈានទៅរកការកាត់បន្ថយភាពក្រីក្រ។

បច្ចុប្បន្ននេះ សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតក្នុងការធ្វើឱ្យជនពិការអាចចូលរួមនៅក្នុងកម្មវិធីនានារបស់រាជរដ្ឋាភិបាល។ ដូច្នេះហើយបានជា ក្រសួងមហាផ្ទៃ អង្គការយូនីសេហ្វ (UNICEF) និងស្ថាប័នដទៃទៀត មានបំណងកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការបង្កលក្ខណៈឱ្យជនពិការបានចូលរួមក្នុងអភិបាលកិច្ច និងការអភិវឌ្ឍ។

**១.២. គោលដៅនៃវគ្គបណ្តុះបណ្តាល** ៖ នៅចុងវគ្គបណ្តុះបណ្តាលនេះ អ្នកចូលរួមអាច ៖

- ប្រើប្រាស់ទិន្នន័យរួមអំពីពិការភាពក្នុងស្រុករបស់ខ្លួន និងប្រើប្រាស់ទិន្នន័យនេះសម្រាប់គោលបំណងនៃការរៀបចំផែនការ
- ស្វែងយល់ពីភាពខុសប្លែកគ្នារវាងភាពខ្សោយ និងពិការភាព
- ស្វែងយល់ និងជម្នះចំពោះការយល់ឃើញរបស់សង្គមអំពីពិការភាព
- ពិនិត្យផ្ទៀងផ្ទាត់ដឹងថារាល់អគារសាធារណៈ កន្លែងផ្តល់សេវា និងកន្លែងប្រជុំដែលមានស្រាប់ និងសង់ថ្មីទាំងអស់ មានភាពងាយស្រួលចេញចូលស្របទៅតាមស្តង់ដាដែលត្រូវបានទទួលយកនៅថ្នាក់អន្តរជាតិ
- យល់ដឹងពីការទទួលខុសត្រូវនៅរដ្ឋបាលឃុំ សង្កាត់ និងសារសំខាន់ៗពាក់ព័ន្ធជាមួយនឹងការបញ្ចូលពិការភាព
- វាយតម្លៃលើដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិនិយោគអំពីការបញ្ចូលពិការភាព
- ធានាបានថាព័ត៌មានសាធារណៈដែលផ្សព្វផ្សាយដោយក្រុង ស្រុក ខណ្ឌ មានភាពងាយស្រួលយល់សម្រាប់ជនពិការ។



[1] ការដាក់បញ្ចូលជនពិការ យេនឌ័រ កុមារ ចាស់ជរា ជនជាតិភាគតិច និងជនងាយរងគ្រោះ

## ១.៣. កាលវិភាគបណ្តុះបណ្តាល

| ពេលវេលា | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ |
|---|---|---|---|
| ៨:០០-១១:៣០ | ជំពូកទី១ ៖ ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល<br>ជំពូកទី២ ៖ ចំណេះដឹងជាមូលដ្ឋានអំពីពិការភាព និងការដាក់បញ្ចូលពិការភាព | ជំពូកទី៣ ៖ ការបង្ហាញពីការគោរព និងសេចក្តីថ្លៃថ្នូរ<br>ជំពូកទី៤ ៖ ការប្រាស្រ័យទាក់ទងជាមួយជនពិការ | ជំពូកទី៥ ៖ ការបង្កើតបរិស្ថានដែលគ្មានឧបសគ្គរាំងដល់ជនពិការ(ត)<br>ជំពូកទី៦ ៖ ការធានាឱ្យមានការចូលរួមយ៉ាងសកម្ម |
| ១១:៣០-១៣:៣០ | **អាហារថ្ងៃត្រង់** | | |
| ១៣.៣០-១៧.០០ | ជំពូកទី២ ៖ ចំណេះដឹងជាមូលដ្ឋានស្តីពីពិការភាព និងការដាក់បញ្ចូលពិការភាព(ត) | ជំពូកទី៤ ៖ ការប្រាស្រ័យទាក់ទងជាមួយជនពិការ (ត)<br>ជំពូកទី៥ ៖ ការបង្កើតបរិស្ថានដែលគ្មានឧបសគ្គរាំងដល់ជនពិការ | ជំពូកទី៧ ៖ ការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការកសាងផែនការ<br>ជំពូកទី៨ ៖ ការវាយតម្លៃវគ្គបណ្តុះបណ្តាល និងបញ្ជីអង្គការសង្គមស៊ីវិលដែលធ្វើការងារពិការភាព |

**កំណត់សម្គាល់ ៖**

- ពេលព្រឹកសម្រាកអាហារសម្រន់១៥នាទី ពីម៉ោង ៩:៣០-៩:៤៥
- ពេលល្ងាចសម្រាកអាហារសម្រន់១៥នាទី ពីម៉ោង ១៥:៣០-១៥:៤៥

# ជំពូកទី១

# ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល

## ថ្ងៃទី ១

# ជំពូកទី១

# ការចាប់ផ្តើមវគ្គបណ្តុះបណ្តាល

តើអ្នកចង់រៀនអ្វីខ្លះក្នុងការបណ្តុះបណ្តាលនេះ ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................។



# ជំពូកទី២
# ចំណេះដឹងជាមូលដ្ឋានអំពី
# ពិការភាព និង
# ការដាក់បញ្ចូលពិការភាព

# ជំពូកទី២
# ចំណេះដឹងជាមូលដ្ឋានអំពីពិការភាព និងការបញ្ចូលពិការភាព

## ករណីសិក្សា

### ១. រឿងរបស់ស្រីមុំ



**ស្រីមុំ** កើតមកដោយមានលលាដ៍ក្បាលធំខុសធម្មតា។ នាងពិការអវៈយវៈនៅពេលដែលនាងធំដឹងក្តី។ នេះមានន័យថា ស្រីមុំ មិនអាចធ្វើដំណើរទៅណាមកណាតែឯងឡើយ។ ដោយសារតែស្រីមុំ រស់នៅក្នុងភូមិជនបទ ហើយគ្រួសាររបស់នាងរវល់នឹងការងារស្រែ ចំការជារឿយៗ នាងត្រូវបានគេទុកចោលនៅផ្ទះ។ នៅពេលដែលស្រីមុំអាយុបាន៦ឆ្នាំ នាងចង់ទៅរៀន ប៉ុន្តែម្តាយរបស់នាងមិនឱ្យទៅ ដោយសារតែគាត់គិតថា ស្រីមុំរៀនមិនចេះនោះទេ។

នៅក្នុងភូមិនេះមានជនពិការមួយក្រុម ពួកគាត់បានណែនាំស្រីមុំឱ្យស្គាល់អង្គការមិនមែនរដ្ឋាភិបាលមួយដែលមានឈ្មោះថា អង្គការសកម្មភាពពិការភាព និងការអភិវឌ្ឍ ADD។ ADD បានជួលគ្រូឱ្យចាប់ផ្តើមបង្រៀន ស្រីមុំ នៅផ្ទះ។ នៅពេលដែលម្តាយរបស់នាងឃើញការរីកចម្រើនរបស់នាង គាត់ចាប់ផ្តើមមានមោទនភាពចំពោះកូនស្រីរបស់គាត់។ ស្រីមុំ បានទៅប្រលងជាមួយនឹងក្មេងផ្សេងទៀត។ នាងជាប់លេខ៤ក្នុងចំណោមកូនសិស្ស៤២នាក់ ហើយឥឡូវនេះចាប់ផ្តើមរៀនថ្នាក់ទី៥។ ឪពុកម្តាយរបស់នាងគាំទ្រពេញទំហឹងដល់ការប្តេជ្ញាចិត្តរបស់ ស្រីមុំ ដើម្បីឱ្យនាងរៀនចប់ចុងចប់ដើម។

## ២. រឿងរបស់ថាវី



**ថាវី** គឺជាស្ត្រីរៀបការហើយមានអាយុ៣០ឆ្នាំ។ នាងបាត់បង់លទ្ធភាពគំហើញរបស់នាង បន្តិចម្តងៗ ហើយក្លាយជាជនពិការភ្នែក។ ប្តីរបស់នាងដែលជាអ្នកស៊ីឈ្នួលគេប្រចាំថ្ងៃ ពេលខ្លះគ្មានការងារធ្វើ ហើយគ្រួសារនេះមិនអាចធានាមានអាហារពីរពេលប្រចាំថ្ងៃឡើយ។ វាគឺជាជីវិតដ៏សែនលំបាក ហើយ ថាវី តែងតែនៅផ្ទះ។ បើទោះបីជា នាងបានរៀនចប់សាលាបឋមសិក្សាយ៉ាងណាក៏ដោយ នាងមិនអាចអានបានទៀតឡើយ ហើយត្រូវពឹងផ្អែកលើអ្វីដែលគេប្រាប់នាង និងអ្វីដែលនាងស្តាប់ឮតាមវិទ្យុ។ ដើម្បីទៅចូលរួមក្នុងកិច្ចប្រជុំក្នុងសហគមន៍ នាងត្រូវពឹងឱ្យមនុស្សផ្សេងទៀតប្រាប់នាង ហើយយកនាងទៅ។ ប៉ុន្តែវាមិនមែនចេះតែបែបនេះ ញឹកញាប់នោះទេ អ្វីៗមានការប្រែប្រួល នៅពេលថាវីត្រូវបានជ្រើសរើសឱ្យចូលរួមនៅក្នុងគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាលមួយ និងបានទទួលការបណ្តុះបណ្តាលអំពីការចិញ្ចឹមពពែ និងការចិញ្ចឹមមាន់។ នាង ក៏បានទទួលពពែ និងកូនមាន់ សម្រាប់ចាប់ផ្តើមចិញ្ចឹម ជាសកម្មភាពរកចំណូលរបស់នាងផងដែរ។ ថាវី មើលថែស្មួនដំណាំ ពពែ និងមាន់ ដោយខ្លួនឯង។ ប៉ុន្តែ នាងបានឱ្យសមាជិកគ្រួសាររបស់នាងទាក់ទងការិយាល័យបសុពេទ្យឱ្យមកចាក់វ៉ាក់សាំង និងផ្តល់ការថែទាំសុខភាពផ្សេងទៀតដល់ពពែ និងបក្សីរបស់នាង។ ប្តីរបស់នាងទៅលក់បន្លែ និងស៊ុតក្នុងផ្សារ។ ដោយសារគាត់មានសួនដំណាំ និងការចិញ្ចឹមសត្វ (ពពែ និងមាន់) ធ្វើឱ្យសន្តិសុខស្បៀងរបស់គ្រួសារមានភាពប្រសើរជាងមុន។ ថាវី ក៏អាចសន្សំលុយបានខ្លះៗ ជាមួយនឹងក្រុមនៅក្នុងភូមិរបស់នាងផងដែរ។ “ខ្ញុំមើលមិនឃើញ ប៉ុន្តែខ្ញុំមានអារម្មណ៍ដឹងពីស្នាមញញឹមនៃសមាជិកគ្រួសាររបស់ខ្ញុំ ដោយសារគ្រួសាររបស់ខ្ញុំមានអាហារសម្រាប់ហូបគ្រប់គ្រាន់។ ប្រសិនបើយើងអាចបន្តការងារនេះទៀត យើងនឹងមិនធ្លាក់ចុះទៅក្នុងភាពក្រីក្រតោកយ៉ាកនោះទេ”។

## ៣. រឿងរបស់សុផល



**សុផល** មានអាយុ២០ឆ្នាំ។ គាត់មានការលំបាកក្នុងការស្តាប់ឮពីអ្នកដទៃនិយាយ នៅពេលដែលគាត់ទៅរៀន។ គាត់មិនអាចទំនាក់ទំនងជាមួយនឹងមនុស្សផ្សេងទៀត នៅក្នុងថ្នាក់របស់គាត់បានឡើយ។ នៅក្នុងគ្រួសាររបស់គាត់ នៅពេលដែលឪពុកម្តាយរបស់គាត់ហៅគាត់ គាត់មានការលំបាកក្នុងការប្រាស្រ័យទាក់ទង។ នៅតាមផ្លូវទៅសាលា គាត់មានការលំបាក ដោយសារតែគាត់ជាមនុស្ស គ ថ្លង់។ នៅពេលខ្លះមានម៉ូតូ ឬកង់ជិះមកជិតគាត់ សុផលស្ទើរតែត្រូវបានម៉ូតូ ឬកង់បុក ដោយសារគាត់ស្តាប់មិនលឺ។

នៅពេលដែលគាត់មានជំងឺ ម្តាយរបស់គាត់យកគាត់ទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ។ ម្តាយរបស់គាត់យកគាត់ទៅផ្នែកត្រចៀករបស់មន្ទីរពេទ្យ ប៉ុន្តែសុផលមានការលំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយបុគ្គល(គិលានុបដ្ឋាក និងវេជ្ជបណ្ឌិត)មន្ទីរពេទ្យ។ ឥឡូវនេះ គាត់មានអ្នកបកប្រែ ហើយនៅពេលដែលគាត់ទៅមន្ទីរពេទ្យម្តងៗ គាត់មានអ្នកបកប្រែមកពីអង្គការ DDP សម្រាប់ជួយគាត់។

គាត់រៀនភាសាសញ្ញាពីកម្មវិធីអភិវឌ្ឍន៍មនុស្សគ ថ្លង់។ គាត់ចាប់ផ្តើមរៀននៅពេលដែលគាអាយុ ១២ឆ្នាំ។ នៅពេលដែលគាត់ទៅសាលារៀន និងជួបជាមួយជនពិការគថ្លង់ផ្សេងទៀត គាត់អាចទំនាក់ទំនងជាមួយអ្នកទាំងនោះបាន ហើយគាត់សប្បាយចិត្តយ៉ាងខ្លាំង។

ឥឡូវនេះ គាត់កំពុងរៀនជំនាញជួសជុលម៉ូតូ។ សុផលពិតជាចង់ធ្វើការងារ ដោយប្រើប្រាស់ជំនាញរបស់គាត់ណាស់ ដើម្បីអាចជួយដល់គ្រួសាររបស់គាត់។ ពេលខ្លះ សុផលមានបញ្ហា ប៉ុន្តែអ្នកគ្រប់គ្រងរបស់គាត់បានជួយគាត់ដោះស្រាយបញ្ហាទាំងនោះ។ សុផលសង្ឃឹមថា មនុស្សទាំងអស់យល់ដឹងថា ជនពិការគ ថ្លង់មានសិទ្ធិដូចគ្នានឹងមនុស្សផ្សេងទៀតដែរ។

ឥឡូវនេះ សុផលមានមិត្តស្រី ហើយគាត់អាចទំនាក់ទំនងបានយ៉ាងងាយជាមួយនាង ដោយសារតែនាងក៏ជាជនពិការគ ថ្លង់ដែរ។

## ៤. រឿងរបស់មករា



**មករា** គឺជាបុរសអាយុ២៣ឆ្នាំ មកពីខេត្តកំពត ដែលមានបំណងចង់ធ្វើស្រែចំការ និងស្រលាញ់ការងារជាគ្រូបង្រៀន។ ដោយសារតែគាត់មានបញ្ហាប្រព័ន្ធបញ្ហាចលនា មករា ពុំមានភាពងាយស្រួលក្នុងការដើរចំងាយឆ្ងាយ ឬនិយាយបានច្បាស់ឡើយ ប៉ុន្តែការលំបាកធំជាងគេរបស់គាត់ គឺការរើសអើងដែលគាត់ត្រូវជំនះពេញមួយជីវិតរបស់គាត់។

ឪពុកម្តាយរបស់ខ្ញុំបានបញ្ជូនខ្ញុំឱ្យទៅរៀននៅសាលាបឋមសិក្សាមួយ។ នៅពេលដែលគ្រូប្រាប់ឱ្យយើងលើកដៃក្នុងថ្នាក់ ខ្ញុំពិបាកធ្វើចលនាបញ្ហាដៃទាំងពីរ ដោយសារតែភាពតឹងរបស់សាច់ដុំដែលធ្វើឱ្យគ្រូវាយខ្ញុំ។ ខ្ញុំបោះបង់ចោលការសិក្សានៅថ្នាក់ទី៦ ដោយសារតែអនុវិទ្យាល័យ នៅឆ្ងាយពីផ្ទះរបស់ខ្ញុំ ហើយខ្ញុំមានការពិបាកក្នុងការដើរទៅទីនោះ។ ខ្ញុំនៅផ្ទះអស់រយៈពេល១០ឆ្នាំ ជួយឪពុកម្តាយរបស់ខ្ញុំធ្វើស្រែ និងដាំបន្លែ។ ខ្ញុំមិនចង់ជួបមនុស្សប្លែកមុខឡើយ ដោយសារតែខ្ញុំគិតថា ពួកគាត់នឹងខ្លាចខ្ញុំ ហើយគិតថា ខ្ញុំជាមនុស្សឆ្កួត ដោយសារតែពិការភាពរបស់ខ្ញុំ។

នៅខែ មករា ឆ្នាំ២០១១ អង្គការមិនមែនរដ្ឋាភិបាលមួយបានបើកមណ្ឌលថែទាំកុមារមួយ (Day Center) នៅជិតផ្ទះ មករា។ បុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលមួយបានអញ្ជើញមករា ឱ្យមកកាន់មណ្ឌលនេះ ៖ "យើងឃើញថា មករា ដឹងរឿងច្រើន ដូច្នេះយើងសួរគាត់ថាតើគាត់អាចបង្រៀនក្មេងៗជាមួយនឹងយើងដែរឬទេ។ ដំបូង គាត់និយាយថា គាត់មិនអាចបង្រៀនបានឡើយ ដោយសារតែគាត់ជា "ជនពិការ"។ យើងបានលើកទឹកចិត្តឱ្យគាត់ដឹងថា មានជនពិការជាច្រើននាក់ ដែលអាចធ្វើកិច្ចការបានជាច្រើន។ គាត់យល់ព្រមចាប់ ផ្តើមជួយក្មេងតូចៗ ហើយឥឡូវនេះ គាត់ខុសប្លែកពីមុន ហើយមានទំនុកចិត្តជាងមុនច្រើន។"

នៅពេលដែលបុគ្គលិករបស់អង្គការនេះ ចាប់ផ្តើមឃើញពីបំណងប្រាថ្នាចង់បង្កបង្កើនផលរបស់មករា ពួកគេបានលើកទឹកចិត្តឱ្យ មករា ពិចារណាចូលរួមក្នុងវគ្គសិក្សាជំនាញកសិកម្ម ដើម្បីរៀនសូត្រជំនាញថ្មីៗ យកទៅប្រើប្រាស់នៅក្នុងស្រែចំការរបស់គ្រួសារគាត់។ បច្ចុប្បន្ន គាត់កំពង់បានចូលរៀន ៣ សប្តាហ៍ហើយ នៅក្នុងវគ្គសិក្សារយៈពេល៦ខែ។ មករា ជាមនុស្សដែលមានការប្រុងប្រយ័ត្ន ប៉ុន្តែគាត់មានការរំភើបចំពោះអនាគតរបស់គាត់។ "ពេលបច្ចុប្បន្ននេះ គ្រួសាររបស់ខ្ញុំគ្រាន់តែធ្វើស្រែ និងដាំបន្លែប៉ុណ្ណោះ ប៉ុន្តែក្រោយពេលដែលខ្ញុំរៀនចប់វគ្គនេះ ខ្ញុំសង្ឃឹមថា យើងនឹងអាចសាកល្បងអ្វីដែលថ្មី ដូចជាចិញ្ចឹមសត្វ និងចាប់ផ្តើមចិញ្ចឹមត្រីជាដើម។ ដោយសារតែខ្ញុំបានចូលរួមជាមួយនឹងអង្គការនេះ ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានផ្លាស់ប្តូរច្រើន។ ខ្ញុំបានជួបមនុស្សជាច្រើននាក់ និងរៀនបានច្រើន។ ឥឡូវនេះ ខ្ញុំលែងបារម្ភថា អ្នកដទៃគិតមកលើរូបខ្ញុំជាមនុស្សឆ្កួតទៀតហើយ! ខ្ញុំមានអារម្មណ៍ធម្មតា។"

## ៥. រឿងរបស់បុប្ផា

**បុប្ផា** គឺជាស្ត្រីអាយុ៣០ឆ្នាំ ដែលមានពិការខ្សោយសតិបញ្ញា ហើយរស់នៅជាមួយម្តាយរបស់នាង ឈ្មោះ យាយ ដា។ បុប្ផា អាចចូលរួមក្នុងក្រុមស្ត្រីប្រចាំភូមិ ក្នុងនាមជាសមាជិករបស់ក្រុមនេះ នាងទទួលបានពពែ២ក្បាល និងមាន់១០ក្បាល។ នៅពេលដែលពពែ២ក្បាលនេះ កើតកូនចំនួន៤ក្បាល បុប្ផាចែកកូន២ក្បាល ទៅឱ្យស្ត្រីម្នាក់ទៀតដែលចូលរួមក្នុងក្រុមស្ត្រីជាមួយនាងដែរ។

ពេលខ្លះបុប្ផា មានការលំបាកក្នុងការយល់ពីអ្វីដែលគេនិយាយ និងមិនអាចនិយាយបានឡើយ ប៉ុន្តែនាងអាចប្រាស្រ័យទាក់ទង ដោយប្រើដៃជាសញ្ញា កាយវិការ និងទំនាក់ទំនងតាមកែវភ្នែក។ នាងប្រមូលពងមាន់ជារៀងរាល់ថ្ងៃ ហើយម្តាយរបស់នាងយកទៅលក់នៅផ្សារ។ បើទោះបីជាម្តាយរបស់នាងជួយនាងបានតិចតួចក៏ដោយ នាងទទួលខុសត្រូវចំពោះសត្វរបស់នាងខ្លាំងណាស់។

នៅពេលដែល យាយ ដា និងបុប្ផា ចង់ដាក់លុយខ្លះក្នុងធនាគារសម្រាប់បុប្ផា គាត់ជួបនឹងការលំបាកជាច្រើន ពួកគាត់ទៅធនាគារ ប៉ុន្តែបុគ្គលិកធនាគារមិនចង់បើកគណនីធនាគារឱ្យមនុស្ស "ខុសធម្មតា" នោះទេ។ នៅថ្ងៃបន្ទាប់ ពួកគាត់ទៅធនាគារម្តងទៀត ហើយសួររកអ្នកគ្រប់គ្រងធនាគារ និងដាក់ពាក្យសុំបើកគណនីធនាគារម្តងទៀត។ ចុងក្រោយ អ្នកគ្រប់គ្រងរូបនេះអនុញ្ញាត និងឱ្យបុប្ផាចុះហត្ថលេខា ប៉ុន្តែបុប្ផាមិនអាចចុះហត្ថលេខាបានឡើយ។ ម្តាយរបស់នាងសុំឱ្យអ្នកគ្រប់គ្រងធនាគារទទួលយកស្នាមមេដៃរបស់បុប្ផាជំនួសវិញ។ អ្នកគ្រប់គ្រងបានអនុញ្ញាត ហើយ បុប្ផា បានក្លាយជាអតិថិជនម្នាក់របស់ធនាគារនេះ។ យាយ ដា និង បុប្ផា សប្បាយចិត្តយ៉ាងខ្លាំងនៅពេលដែលពួកគាត់ទទួលបានជោគជ័យ។

# កំណត់សម្គាល់ផ្ទាល់ខ្លួន

....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................
....................................................................................................។

### ២.១. និយមន័យពិការភាព

ជារឿយៗ ពិការភាព និងភាពខ្សោយ តែងត្រូវបានប្រើហាក់បីដូចជាពាក្យទាំងពីរនេះមានន័យដូចគ្នាដែរ។ ប៉ុន្តែតាមពិតពាក្យនេះមានន័យខុសគ្នា ៖

- **ភាពខ្សោយ** គឺជាការបាត់បង់មុខងារណាមួយរបស់រាងកាយ។ ឧទាហរណ៍ នៅពេលដែលអ្នកណាម្នាក់មិនអាចមើលឃើញច្បាស់ជាដើម។ ភាពខ្សោយ ភាគច្រើនមិនអាចកែមកវិញបានឡើយ និងអូសបន្លាយពេលពេញមួយជីវិត។ ប៉ុន្តែពេលខ្លះ គេអាចកែកុនភាពខ្សោយនេះបាន ដូចជា នៅក្នុងករណីគំហើញ ដោយប្រើប្រាស់វ៉ែនតាជាដើម។
- **ពិការភាព** គឺនៅពេលដែលមនុស្សម្នាក់មានភាពខ្សោយ និងជួបប្រទះឧបសគ្គក្នុងការធ្វើសកម្មភាពអ្វីមួយ។

*ភាពខ្សោយ + ឧបសគ្គ = ពិការភាព*

ឧទាហរណ៍ ៖ ប្រសិនបើមនុស្សម្នាក់មានបញ្ហាភ្នែក ដែលមិនអាចព្យាបាលបាន បណ្តាលឱ្យគាត់មិនអាចអានឯកសារបោះពុម្ពបាន។ ប៉ុន្តែវាពុំមានបញ្ហាសម្រាប់គាត់នោះទេ ប្រសិនបើ ឯកសារនោះជាអក្សរស្ទាប។ ដូច្នេះ ភាពខ្សោយពុំមែនជាបញ្ហានោះទេ ប៉ុន្តែឧបសគ្គទៅវិញទេដែលធ្វើឱ្យមានបញ្ហាសម្រាប់ជនពិការក្នុងការចូលរួមក្នុងសកម្មភាពនានាដូចអ្នកផ្សេងទៀត។

**សារគន្លឹះ**

- ភាពខ្សោយ គឺជាការបាត់បង់មុខងារណាមួយរបស់រាងកាយ
- ពិការភាពមិនមែនជាការបាត់បង់មុខងារណាមួយរបស់រាងកាយនោះទេ
- ពិការភាព គឺពាក់ព័ន្ធជាមួយនឹងឧបសគ្គក្នុងបរិស្ថាន ឬឥរិយាបថរបស់មនុស្សដែលរារាំងជនពិការមិនឱ្យធ្វើសកម្មភាពប្រចាំថ្ងៃ ក្នុងការចូលរួមក្នុងសកម្មភាពនានាដូចអ្នកផ្សេងទៀត។

### ២.២. ប្រភេទផ្សេងៗនៃភាពខ្សោយ

មនុស្សអាចមានភាពខ្សោយច្រើនប្រភេទផ្សេងៗគ្នា។ ភាពខ្សោយខ្លះអាច មើលឃើញជាក់ស្តែង ហើយភាពខ្សោយខ្លះទៀតពិបាកមើលឃើញ។ ខាងក្រោមនេះ គឺជាបញ្ជីនៃប្រភេទភាពខ្សោយ ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ៖

- **ពិបាកមើល ៖** ខ្សោយគំហើញ (ដូចជា ថារី ជាដើម)
- **ពិបាកស្តាប់ ៖** ខ្សោយខាងការស្តាប់ (ដូចជា សុផល ជាដើម)
- **ពិបាកធ្វើចលនា ឬប្រើប្រាស់ផ្នែកនៃរាងកាយ៖** ខ្សោយខាងចលនារាងកាយ (ដូចជា ស្រីមុំ ឬ មករា ជាដើម)

- **ពិបាកចងចាំ ឬផ្ចង់ស្មារតី ឬពិបាកថែទាំខ្លួនឯង ៖** ខ្សោយខាងបញ្ញាស្មារតី (ដូចជា បុប្ផា ជាដើម)
- **ពិបាកនិយាយ ៖** ខ្សោយខាងនិយាយ

**កំណត់សម្គាល់ ៖**

នៅក្នុងករណីភាគច្រើន អ្នកដែលមានភាពខ្សោយក៏ជាជនពិការផងដែរ ដោយសារតែឧបសគ្គជាច្រើនក្នុងសង្គម។ ដូច្នេះ នៅក្នុងការបណ្តុះបណ្តាលនេះ យើងនឹងនិយាយសំដៅលើជនពិការ។

**ប្រមូលទិន្នន័យ**

វាជាការសំខាន់ ដែលត្រូវដឹង តើអ្នកណាខ្លះជាជនពិការនៅក្នុងក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យអ្នកអាចបញ្ចូលពួកគាត់ និងផ្តល់ការគាំទ្រដល់ពួកគាត់ឱ្យបានល្អ។

ការកំណត់រកជនពិការ មិនមែនចេះតែងាយស្រួលនោះទេ។ ពេលខ្លះ ជនពិការលាក់ខ្លួននៅក្នុងផ្ទះ ហើយមិនសូវជាចេញមកខាងក្រៅនោះទេ។ ពេលខ្លះ ពិការភាពមិនអាចមើលឃើញពីខាងក្រៅឡើយ ឧទាហរណ៍ ៖ នៅពេលដែលអ្នកណាម្នាក់មើលមិនឃើញច្បាស់ជាដើម។ ឬជនពិការ ប្រហែលជាមិនចង់ចាត់ទុកខ្លួនឯងថាជាជនពិការ ដោយសារតែការភ័យខ្លាចទទួលរងការមាក់ងាយ ឬការរើសអើង។

ពេលខ្លះ មានទិន្នន័យ ដែលគេអាចយកមកប្រើប្រាស់បានតែម្តង។ ឧទាហរណ៍ ៖ ទិន្នន័យពីជំរឿន ទិន្នន័យពីកម្មវិធីអប់រំ ឬទិន្នន័យពីផែនទីសេវាសង្គម ឬកម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍នៅក្នុងតំបន់ពីរាជរដ្ឋាភិបាល ឬពីអង្គការជនពិការនៅមូលដ្ឋានជាដើម។

នៅក្នុងករណីផ្សេងទៀត គេប្រហែលជាចាំបាច់ត្រូវធ្វើការប្រមូលទិន្នន័យ ដោយសារតែមិនទាន់មានទិន្នន័យនៅឡើយ។ គេអាចប្រមូលទិន្នន័យតាមរបៀបផ្សេងៗ ឧទាហរណ៍ ៖ អ្នកអាចសួរទៅអង្គការជនពិការពីជនពិការដែលពួកគាត់ស្គាល់។ អ្នកក៏អាចសុំទៅអ្នកដឹកនាំសហគមន៍ជួយកំណត់រកជនពិការនៅក្នុងសហគមន៍របស់ពួកគាត់ ដូចជា តាមរយៈការទៅកាន់ផ្ទះទាំងអស់នៅក្នុងតំបន់របស់ពួកគាត់។

ក្នុងការបណ្តុះបណ្តាលនេះ មានបញ្ជីសំណួរសម្រាប់កំណត់អត្តសញ្ញាណជនពិការខាងក្រោមត្រូវបានប្រើប្រាស់ ដើម្បីកំណត់រកប្រភេទ និងកម្រិតនៃភាពខ្សោយផ្សេងៗគ្នា។ នេះគ្រាន់តែជាការណែនាំប៉ុណ្ណោះ ប៉ុន្តែវាអាចផ្តល់ជាគំនិតដល់អ្នកពីរបៀបដែលអ្នកអាចយកទៅអនុវត្តក្នុងបរិបទផ្ទាល់ខ្លួន។

**សំណួរកំណត់អត្តសញ្ញាណជនពិការ**

១. តើអ្នកមានការពិបាកក្នុងការមើលដែរឬទេ សូម្បីតែពាក់វ៉ែនតាក៏ដោយ?
ក). ទេ - មិនពិបាកអ្វីទេ
ខ). បាទ/ចាស - ពិបាកខ្លះដែរ
គ). បាទ/ចាស - ពិបាកខ្លាំង
ឃ). មិនអាចមើលឃើញសោះតែម្ដង

២. តើអ្នកមានការពិបាកក្នុងស្ដាប់ដែរឬទេ សូម្បីតែប្រើប្រាស់ឧបករណ៍ជំនួយការស្ដាប់ក៏ដោយ?
ក). ទេ - មិនពិបាកអ្វីទេ
ខ). បាទ/ចាស - ពិបាកខ្លះដែរ
គ). បាទ/ចាស - ពិបាកខ្លាំង
ឃ). មិនអាចស្ដាប់ឮសោះតែម្ដង

៣. តើអ្នកមានការពិបាកក្នុងការផ្លាស់ទី ឬឡើងជណ្ដើរដែរឬទេ?
ក). ទេ - មិនពិបាកអ្វីទេ
ខ). បាទ/ចាស - ពិបាកខ្លះដែរ
គ). បាទ/ចាស - ពិបាកខ្លាំង
ឃ). មិនអាចធ្វើបានសោះតែម្ដង

៤. តើអ្នកមានការពិបាកក្នុងការចងចាំ ឬផ្ចង់អារម្មណ៍ដែរឬទេ?
ក). ទេ - មិនពិបាកអ្វីទេ
ខ). បាទ/ចាស - ពិបាកខ្លះដែរ
គ). បាទ/ចាស - ពិបាកខ្លាំង
ឃ). មិនអាចធ្វើបានសោះតែម្ដង

៥. តើអ្នកមានការពិបាកក្នុងការថែទាំខ្លួនឯងដែរឬទេ ដូចជាការងូតទឹក ឬស្លៀកពាក់?
ក). ទេ - មិនពិបាកអ្វីទេ
ខ). បាទ/ចាស - ពិបាកខ្លះដែរ
គ). បាទ/ចាស - ពិបាកខ្លាំង
ឃ). មិនអាចធ្វើបានសោះតែម្ដង

៦. ដោយប្រើប្រាស់ភាសាធម្មតា (តាមទម្លាប់) របស់អ្នក តើអ្នកមានការលំបាកក្នុងការនិយាយដែរឬទេ ឧ. ដូចជា យល់អ្នកដទៃ ឬឱ្យអ្នកដទៃយល់អ្នក ជាដើម?
ក). ទេ - មិនពិបាកអ្វីទេ
ខ). បាទ/ចាស - ពិបាកខ្លះដែរ
គ). បាទ/ចាស - ពិបាកខ្លាំង
ឃ). មិនអាចធ្វើបានសោះតែម្ដង

# កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
..............................................................................................................................................................
...........................................................................................................................................................។

**សារគន្លឹះ:**

ភាពខ្សោយមានច្រើនប្រភេទ។ ភាពខ្សោយមួយចំនួនអាចមើលឃើញជាក់ស្តែង និងមួយចំនួនទៀតមិនបានស្តែងចេញច្បាស់ឡើយ។

| | |
|---|---|
| មានការលំបាកខ្លះ | ចាត់ទុកថាមានភាពខ្សោយ ដូច្នេះជាជនពិការ |
| មានការលំបាកច្រើន | |
| មិនអាចធ្វើបានតែម្តង | |

## ២.៣. ពិការភាពក្នុងប្រទេសកម្ពុជា

### តើមានជនពិការប៉ុន្មាននាក់ រស់នៅក្នុងប្រទេសកម្ពុជា?

- មានមនុស្សជាង១ពាន់លាននាក់ ដែលរស់នៅជាមួយនឹងពិការភាពក្នុងទម្រង់អ្វីមួយ។ នេះស្មើនឹងប្រមាណជា១៥%នៃចំនួនប្រជាជនក្នុងពិភពលោក(មនុស្ស៧នាក់មាន១នាក់មានពិការភាព)។
- បើតាមការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា(CSES) ឆ្នាំ២០១៣ មានប្រជាជនកម្ពុជា ៥% ដែលមានពិការភាព។

### តើអ្នកណាខ្លះ ជាជនពិការ?

- អនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ បានផ្តល់និយមន័យដល់ជនពិការដូចខាងក្រោម ៖

*ជនពិការសំដៅលើអ្នកទាំងឡាយណាដែលមានភាពអន់ខ្សោយរយៈពេលយូរ ផ្នែកកាយសម្បទាផ្លូវចិត្ត សតិបញ្ញា ឬញាណដឹង ដែលនៅពេលជួបប្រទះជាមួយឧបសគ្គនានា អាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គម ដោយស្មើភាពគ្នាជាមួយអ្នកដទៃបាន។*

ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា ជនពិការ គឺជា៖

*ជនពិការសំដៅដល់ជនទាំងឡាយណា ដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬ សតិបញ្ញា បណ្តាលឱ្យមានការរំខានដល់ជីវភាពរស់នៅ ឬ សកម្មភាពនានាប្រចាំថ្ងៃ ដូចជាជនពិការរាងកាយ ពិការភ្នែក ពិការត្រចៀកស្តាប់ ពិការសតិបញ្ញា មនសិការវិកល និងប្រភេទពិការផ្សេងៗទៀត ដែលនាំឱ្យមានលក្ខណៈមិនប្រក្រតី។*

ប្រភេទភាពខ្សោយដែលតែងតែមាននៅក្នុងប្រទេសកម្ពុជារួមមាន ៖

១. ភាពខ្សោយខាងគំហើញ

២. ភាពខ្សោយខាងកាយសម្បទា

៣. ភាពខ្សោយខាងការស្តាប់

ជនពិការភាគច្រើននៅកម្ពុជា ចាប់ផ្តើមមានភាពខ្សោយ ក្រោយពេលកើត។ មូលហេតុភាគច្រើននៃភាពខ្សោយ គឺចាស់ជរា និងរោគាពាធ។ មូលហេតុផ្សេងទៀត រួមមាន គ្រោះថ្នាក់ដោយសារគ្រាប់មីន ឬការរងរបួស ដោយសារសង្គ្រាម និងគ្រោះថ្នាក់ចរាចរណ៍ឬគ្រោះថ្នាក់នៅកន្លែងការងារជាដើម។



## ព័ត៌មានសាវតារអំពីច្បាប់ និងក្របខ័ណ្ឌពិការភាពក្នុងប្រទេសកម្ពុជា

### ក. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធនឹងពិការភាពនៅកម្ពុជា

- **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ជំពូកទី៦ ស្តីពីការអប់រំ វប្បធម៌ និងសង្គមកិច្ច មាត្រា៧៤ ចែងថា "រដ្ឋត្រូវជួយឧបត្ថម្ភជនពិការ និងគ្រួសារយុទ្ធជនដែលបានបូជាជីវិត ដើម្បីប្រទេសជាតិ"។
- **ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ** ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩។ ច្បាប់នេះមានគោលបំណង "ការពារសិទ្ធិនិងសេរីភាពរបស់ជនពិការ ការពារផលប្រយោជន៍ជនពិការ ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនពិការ និង ស្តារកាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ ដើម្បីជានាលទ្ធភាពក្នុងការចូលរួមដ៏ពេញលេញ និង ដោយស្មើភាពគ្នានៃជនពិការក្នុងសកម្មភាពនានារបស់សង្គម"។ (ជំពូកទី១ មាត្រា២)
- រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ នៅថ្ងៃទី០១ ខែតុលា ក្នុងឆ្នាំ២០០៧ និងផ្តល់សច្ចាប័នដល់អនុសញ្ញានេះ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២។

### ខ. ក្របខ័ណ្ឌអភិវឌ្ឍន៍ពាក់ព័ន្ធជាមួយនឹងពិការភាពក្នុងប្រទេសកម្ពុជា

- **ក្រុមប្រឹក្សាសកម្មភាពជនពិការ(DAC)**-DAC គឺជាស្ថាប័នជាតិ ដែលសម្របសម្រួល និងផ្តល់ប្រឹក្សាខាងពិការភាពដល់រាជរដ្ឋាភិបាលកម្ពុជា។ ស្ថាប័ននេះផ្តល់អនុសាសន៍អំពីសិទ្ធិជនពិការ និងជាស្ថាប័នសំខាន់ដែលមានតួនាទីរៀបចំ និងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ ក្រុមប្រឹក្សាសកម្មភាពជនពិការត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពីកិច្ចការពារ និង លើកកម្ពស់សិទ្ធិជនពិការ នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(MOSVY)** ទទួលបន្ទុកជានាសុខុមាលភាពរបស់ជនពិការ និងក្រុមងាយរងគ្រោះផ្សេងទៀត។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គឺជាក្រសួងដែលដឹកនាំការងារបច្ចេកទេស។ រាល់ក្រសួងពាក់ព័ន្ធទាំងអស់សុទ្ធតែមានតួនាទីសំខាន់ក្នុងការអនុវត្តច្បាប់ និងគោលនយោបាយនានា ក៏ដូចជាលើកកម្ពស់សិទ្ធិ និង សុខុមាលភាពរបស់ជនពិការ។ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាជ្ញាធរគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន និងក្រសួងផែនការតាមរយៈវិទ្យាស្ថានជាតិស្ថិតិ ក្រសួងអភិវឌ្ឍន៍ជនបទ។ល។
- **គណៈកម្មាធិការជាតិសម្របសម្រួលពិការភាព(NDCC)** ដោយមានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាប្រធាន គណៈកម្មាធិការជាតិសម្របសម្រួលពិការភាពទទួលបន្ទុកពិនិត្យតាមដាន និងវាយតម្លៃ សម្របសម្រួល និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។
- **ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨** (NDSP) ផែនការនេះត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាសកម្មភាពជនពិការ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព មានគោលបំណងបំពេញទៅតាមកាតព្វកិច្ចដូចមានចែងក្នុង UNCRPD។ ក្រុមប្រឹក្សាសកម្មភាពជនពិការដែលមានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង

យុវនីតិសម្បទាជាប្រធានទទួលខុសត្រូវពិនិត្យតាមដាន និងវាយតម្លៃ សម្របសម្រួល និងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។

- **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨** (ESP) ផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្មី បានដាក់ចេញនូវគោលបំណងជាច្រើន ដែលមានរាប់បញ្ចូលទាំងជនពិការផងដែរ។ ការឆ្លើយតបមួយក្នុងចំណោមការឆ្លើយតបនានាក្នុងផែនការនេះ គឺដើម្បីចាត់វិធានការកាត់បន្ថយចំនួនកុមារក្រៅសាលាជាមួយនឹងការផ្តោតយកចិត្តទុកដាក់លើកុមារពិការ រួមមានការពង្រីកកម្មវិធីអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ ជាពិសេសតាមសាលាមត្តេយ្យ និងផ្តល់ការគាំទ្រដល់កុមារពិការ តាមរយៈការពិនិត្យ និងការផ្តល់ឧបករណ៍ជំនួយនានា។

# កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

## ២.៤. ល្បែងជីវិត

**សារគន្លឹះ៖**

- គម្លាតរវាងបុរសមិនពិការ និងស្ត្រីពិការ មានទំហំធំធេង
- ជនពិការបោះជំហានថយក្រោយ ដោយសារមូលហេតុអ្វីមួយ
- គេហៅមូលហេតុទាំងនេះថាជាឧបសគ្គ ៖ ឧបសគ្គបន្ទុចបង្អាក់ជនពិការមិនឱ្យចូលរួមក្នុងសង្គម។

## កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

.........................................................................................................................................................។

## ២.៥. ឧបសគ្គរបស់ជនពិការ

**អ្វីទៅជាឧបសគ្គ?**

- ឧបសគ្គ អាចរារាំងជនពិការមិនឱ្យធ្វើអ្វីមួយ ដូចមនុស្សផ្សេងទៀតបាន។ ជនពិការអាចពុំមានសមត្ថភាពធ្វើអ្វីមួយបានជាមួយនឹងកាយសម្បទារបស់ពួកគាត់ដូចអ្នកផ្សេងទៀត ប៉ុន្តែប្រសិនបើមជ្ឈដ្ឋានជុំវិញ និងមនុស្សស្វាគមន៍ពួកគាត់នោះ វាមិនគួរជាបញ្ហាឡើយ។ ជនពិការអាចជួបប្រទះនឹងឧបសគ្គ នៅកន្លែងធ្វើការ ក្នុងសង្គម និងនៅផ្ទះ ដែលឧបសគ្គទាំងនោះអាចមានលក្ខណៈផ្សេងៗគ្នាទៅតាមបុគ្គល ដោយសារតែជនពិការមានប្រភេទនៃភាពខ្សោយផ្សេងៗគ្នា ដូចជា នៅពេលដែលជនពិការជាស្ត្រី ឬជាអ្នកមកពីកុលសម្ព័ន្ធជនជាតិភាគតិចជាដើម។ ឧទាហរណ៍ ៖ អ្នកដែលមានពិការភាពខាងកាយសម្បទា អាចជួបការលំបាកក្នុងការផ្លាស់ទីទៅកន្លែងណាមួយ ដូចជានៅពេលដែលមានកិច្ចប្រជុំសហគមន៍ធ្វើឡើងនៅក្នុងវត្ត គេចាំបាច់ត្រូវឡើងជណ្តើរជាដើម។ ប្រសិនបើមានជម្រាលនៅទីនោះ ពួកគាត់នឹងអាចមកចូលរួមក្នុងកិច្ចប្រជុំសហគមន៍នេះជាមិនខាន។
- ឧបសគ្គចែកជា៤ប្រភេទ៖

| | |
|---|---|
| ឥរិយាបថ | នៅពេលដែលគេគិតជាអវិជ្ជមានពីជនពិការ |
| ការប្រាស្រ័យទាក់ទង | តើជនពិការអាចចែករំលែក និងទទួលព័ត៌មាន គំនិត អារម្មណ៍ ដូចអ្នកដទៃបានដែរឬទេ? |
| ភាពងាយស្រួលក្នុងការចេញចូល | តើជនពិការងាយស្រួលចេញចូលអគារមួយ ឬងាយស្រួលទទួលបានសេវាអ្វីមួយដែរឬទេ? ឧទាហរណ៍ ៖ តើជនពិការអាចប្រើប្រាស់បង្គន់ ឬទៅមណ្ឌលសុខភាពបានដែរឬទេ? |
| ការចូលរួម | ជនពិការមិនអាចចូលរួម ឬចែករំលែកអ្វីមួយជាដើម ដូចជា ក្នុងសកម្មភាពសង្គមអ្វីមួយជាដើម។ |

**សារគន្លឹះ:**

- ឧបសគ្គអាចរារាំងជនពិការ មិនឱ្យរស់ក្នុងជីវិតដូចអ្នកដទៃ
- ឧបសគ្គទាំងនេះអាចកើតឡើងដោយសារ ៖
  - ភាពមិនងាយស្រួលក្នុងការចេញចូល
  - ការប្រាស្រ័យទាក់ទងពុំមានប្រសិទ្ធភាព
  - ឥរិយាបថអវិជ្ជមាន
  - ការមិនរាប់រករបស់អ្នកដទៃ
- ជនពិការអាចរស់នៅក្នុងជីវិតពេញលេញ និងជោគជ័យនៅពេលដែលឧបសគ្គនានាត្រូវបានដកចេញ។

| ប្រភេទ | ឧបសគ្គ | ឧទាហរណ៍ |
|---|---|---|
| ឥរិយាបថ | ឥរិយាបថអវិជ្ជមានចំពោះជនពិការ | |
| ការប្រាស្រ័យទាក់ទង | ការប្រាស្រ័យទាក់ទង ពុំមានប្រសិទ្ធភាព ជាមួយជនពិការ | |
| ភាពងាយក្នុងការចេញចូល | អគារមិនអាចចេញចូលបាន សម្រាប់ជនពិការ | |
| ការចូលរួម | ដំណើរការ ដែលធ្វើឱ្យជនពិការនៅឯកោពីគេ | |

## ២.៦. អត្ថប្រយោជន៍នៃការបញ្ចូលពិការភាព

**តើការបញ្ចូលពិការភាពផ្តល់ផលប្រយោជន៍អ្វីខ្លះ?**

- ការបញ្ចូលពិការភាពបង្កើនការផ្តល់តម្លៃដល់ខ្លួនឯងរបស់ជនពិការ។ ជាពិសេស នៅពេលដែលជនពិការមានសកម្មភាពសេដ្ឋកិច្ច ពួកគាត់មានតួនាទីដែលសង្គមផ្តល់តម្លៃឱ្យ ដូចជា សិស្ស និយោជិត ម្ចាស់ហាង ឬជាងជួសជុលម៉ូតូ។
- ការបញ្ចូលពិការភាពមិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់ជនពិការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ផលប្រយោជន៍ដល់សមាជិកគ្រួសាររបស់ជនពិការទៀតផង។ តើនៅចាំទេពីរឿងរបស់ថាវី តើសមាជិកគ្រួសារមានមោទនភាពកម្រិតណា នៅពេលដែលនាងអាចរកចំណូលបាន។
- ការបញ្ចូលពិការភាពក៏ផ្តល់ផលប្រយោជន៍ដល់សង្គមទាំងមូលផងដែរ។ នៅពេលដែលមានមនុស្សកាន់តែច្រើននាក់មានសកម្មភាពក្នុងវិស័យសេដ្ឋកិច្ច នោះការចំណាយលើកម្មវិធីពិសេសសម្រាប់សង្គមនឹងមានការថយចុះ។

**តើមានលទ្ធផលយ៉ាងដូចម្តេចនៃការផាត់ចេញ?**

ដោយសារតែការផាត់ចេញ ៖ ជនពិការក្លាយជាជនក្រីក្រ! ជនក្រីក្រកាន់តែងាយរងគ្រោះ! នៅពេលដែលពួកគាត់ងាយរងគ្រោះពួកគាត់ងាយនឹងមានពិការភាព។ ដូច្នេះ ការបញ្ចូលពិការភាពអាចបញ្ចប់វដ្តនៃភាពក្រីក្របាន។




ការបញ្ចូលពិការភាព មានន័យថាឱ្យមនុស្សគ្រប់គ្នាក្នុងសង្គម អាចចូលរួមក្នុងសកម្មភាពគម្រោង និងកម្មវិធីនានាគ្រប់ដំណាក់កាលទាំងអស់។ ដើម្បីផ្តល់លទ្ធភាពឱ្យគ្រប់គ្នាចូលរួមបាន ចាំបាច់ត្រូវដកឧបសគ្គមួយចំនួនចេញ។ យើងអាចផ្តោតការយកចិត្តទុកដាក់លើការដកចេញនូវឧបសគ្គនានា ដែលពាក់ព័ន្ធជាក់លាក់ជាមួយនឹង ៖

- ឥរិយាបថ ៖ បង្ហាញការគោរព និងសេចក្តីថ្លៃថ្នូរ
- ការប្រាស្រ័យទាក់ទង ៖ ប្រាស្រ័យទាក់ទងជាមួយជនពិការ
- ភាពងាយស្រួលក្នុងការចេញចូល៖ បង្កើតការចេញចូលដោយគ្មានឧបសគ្គ
- ការចូលរួម ៖ ធានាឱ្យមានការចូលរួមឱ្យបានសកម្ម

ឧទាហរណ៍បង្ហាញពីអត្ថប្រយោជន៍នៃការបញ្ចូលពិការភាព






**សារគន្លឹះ**

- អត្ថប្រយោជន៍នៃការបញ្ចូលពិការភាព រួមមាន៖
    - ➢ ចំណូលគ្រួសារខ្ពស់ជាងមុន កាត់បន្ថយចំណាយលើសេវាសុខភាព និងកាត់បន្ថយភាពក្រីក្រ
    - ➢ បង្កើនផលិតភាព និងការអភិវឌ្ឍសេដ្ឋកិច្ច កាត់បន្ថយចំណាយលើកម្មវិធីសុខុមាលភាពសង្គម និងសុខភាព
- គំនិតដែលគួរចងចាំ៖
    - ➢ ការបញ្ចូលពិការភាព **ផ្តល់ផលប្រយោជន៍ដល់ទាំងអស់គ្នា**
    - ➢ ការបញ្ចូលពិការភាព **កាត់បន្ថយភាពងាយរងគ្រោះ**
    - ➢ ការបញ្ចូលពិការភាព **បង្កើនប្រសិទ្ធភាពថែមទៀត**

## កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..........................................................................................................................................។

## សង្ខេបជំពូកទី២

- ភាពខ្សោយ គឺជាការបាត់បង់មុខងាររបស់រាងកាយ
- ពិការភាពកើតឡើងនៅពេលដែលមនុស្សម្នាក់មានភាពខ្សោយ ហើយជួបប្រទះនឹងឧបសគ្គក្នុងការធ្វើសកម្មភាពអ្វីមួយ
- ភាពខ្សោយ + ឧបសគ្គ = ពិការភាព
- មនុស្សអាចមានពិការភាពក្នុងកម្រិតផ្សេងៗពីគ្នា និងប្រភេទខុសៗគ្នា
- ក្នុងចំណោមមនុស្ស៧នាក់មាន១នាក់ជាជនពិការ(សម្រាប់ពិភពលោក)
- ឧបសគ្គរបស់ជនពិការ ៖
    - ➢ ឥរិយាបថ ៖ បង្ហាញពីការគោរព និងសេចក្តីថ្លៃថ្នូរ
    - ➢ ភាពងាយស្រួលក្នុងការចេញចូល ៖ ធ្វើឱ្យមានការចេញចូលដោយពុំមានឧបសគ្គ
    - ➢ ការប្រាស្រ័យទាក់ទង ៖ ចែករំលែកព័ត៌មាន និងគំនិតនានា
    - ➢ ការចូលរួម ៖ ធានាឱ្យមានការចូលរួម
- ការបញ្ចូលពិការភាពកាត់បន្ថយភាពងាយរងគ្រោះ។ ការបញ្ចូលជនពិការផ្តល់ផលប្រយោជន៍ដល់ជនពិការ គ្រួសារ និងសង្គមរបស់ពួកគាត់។
- ការបញ្ចូលពិការភាពមានសារៈសំខាន់ និងអាចលើកកម្ពស់តាមរយៈការលុបបំបាត់ឧបសគ្គចំពោះជនពិការ។

# ជំពូកទី៣
# ការបង្ហាញពីការគោរព និង
# សេចក្តីថ្លៃថ្នូរ

## ថ្ងៃទី២

# ជំពូកទី៣
# ការបង្ហាញពីការគោរព និងសេចក្តីថ្លៃថ្នូរ

### ៣.១. រំឭកមេរៀនថ្ងៃទី១ ៖ សំណួរសាកល្បងការយល់ដឹងអំពីអ្វីដែលជាការពិត និងអ្វីដែលជាការយល់ខុស ឬជំនឿមិនពិតដែលធ្លាប់មានពីមុនមក

| សំណួរ | ចម្លើយត្រឹមត្រូវ |
|---|---|
| **១. តើតួអង្គមួយណា ដែលពិការគ-ថ្លង់ ?**<br>ក ) ថាវី<br>ខ ) ស្រីមុំ<br>គ ) សុផល<br>ឃ )មករា | |
| **២. តើពិការភាពមាននិយមន័យយ៉ាងដូចម្តេច ?**<br>ក ) ពិការភាព គឺជាបញ្ហាកាយសម្បទា<br>ខ ) ពិការភាព គឺដូចគ្នានឹងភាពខ្សោយដែរ<br>គ ) ពិការភាព គឺនៅពេលដែលមនុស្សណាម្នាក់ដែលមានភាពខ្សោយជួបប្រទះនឹងឧបសគ្គ<br>ឃ ) ពិការភាព គឺនៅពេលដែលអ្នកចាំបាច់ត្រូវទៅជួបវេជ្ជបណ្ឌិត | |
| **៣. តើអ្នកណាខ្លះដែលមានពិការភាព ?**<br>ក ) គ្រប់គ្នាមានពិការភាព ក្នុងកម្រិតណាមួយ<br>ខ ) ប្រជាជនត្រឹមតែ ៥% ប៉ុណ្ណោះ ដែលមានពិការភាព<br>គ ) មានតែទាហានប៉ុណ្ណោះ ដែលរងរបួសនៅក្នុងអំឡុងពេលមានសង្គ្រាមកើតមានឡើង<br>ឃ ) មនុស្សមានការលំបាកខ្លះ ការលំបាកច្រើន ឬ មិនអាចធ្វើបានតែម្តង ក្នុងការបំពេញមុខងារមួយ ឬច្រើន | |
| **៤. តើជនពិការអាចទទួលបានជោគជ័យដែរឬទេ ?**<br>ក ) អាច<br>ខ ) មិនអាច | |

| | |
|---|---|
| **៥. តើអ្នកណាខ្លះដែលមានឱកាសច្រើន នៅក្នុងជីវិត?**<br>ក) បុរសមិនពិការ<br>ខ) ស្ត្រីពិការ<br>គ) បុរសពិការ<br>ឃ) ស្ត្រីមិនពិការ | |
| **៦. សូមជ្រើសរើសយកជម្រើសដែលមិនមែនជាឧបសគ្គ ៖**<br>ក) ឥរិយាបថអវិជ្ជមានរបស់គ្រូ<br>ខ) អគារ ដែលពិបាកចេញចូល<br>គ) អ្នកដែលស្រែកខ្លាំងៗដាក់ជនពិការគ-ថ្លង់<br>ឃ) អ្នកដែលពិការអវៈយវៈដែលមិនអាចផ្លាស់ទីបាន | |
| **៧. តើឧបសគ្គមានដូចៗ គ្នាចំពោះជនពិការដែរឬ ទេ?**<br>ក) ដូចគ្នា<br>ខ) មិនដូចគ្នាទេ | |
| សំណួរបន្ថែម ៖ **តើអ្នកយល់ស្រប ឬមិនយល់ស្រប នឹងប្រយោគខាងក្រោម ៖ ជនពិការគួរមើលថែខ្លួនឯង វាមិនមែនជាការទទួលខុសត្រូវរបស់សហគមន៍នោះទេ ៖**<br>ក) យល់ស្រប<br>ខ) មិនយល់ស្រប | |

តើអ្នករៀនបានអ្វីខ្លះនៅថ្ងៃទី១?

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

..............................................................................................................................។

## ៣.២. ឥរិយាបថចំពោះពិការភាព

**ឥរិយាបថ (Attitude)**

ឥរិយាបថ គឺជារបៀបដែលមនុស្សម្នាក់ធ្វើការវាយតម្លៃឬវិនិច្ឆ័យទៅលើបុគ្គលណាម្នាក់ វត្ថុ ព្រឹត្តិការណ៍ ឬគំនិតអ្វីមួយ។ ឥរិយាបថត្រូវបានរៀបរាប់ខុសៗគ្នា ឥរិយាបថ គឺជារបៀបដែលយើងគិតពីអ្នកណាម្នាក់ ឬអ្វីមួយ។ ការគិតនោះអាចជាគំនិតវិជ្ជមាន ឬគំនិតអវិជ្ជមាន។ ជារឿយៗ របៀបដែលយើងគិតអំពីអ្វីមួយមានឥទ្ធិពលលើរបៀបដែលយើងធ្វើសកម្មភាពជាក់ស្តែង។

> *ជនពិការនិយាយថា ឥរិយាបថអវិជ្ជមានអំពីពិការភាព គឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗជាងគេដែលពួកគាត់ជួបប្រទះ!*

ជារឿយៗ គេផាត់ជនពិការចេញ ដោសារតែគេមានគំនិតអវិជ្ជមានឬខុសពីជនពិការ ដូចជា គំនិតដែលថាពិការភាពត្រូវបានគេចាត់ទុកថាជាបណ្តាសារ ឬគំនិតដែលថា ជនពិការ គឺជាមនុស្សដែលគួរឱ្យអាណិតជាដើម។ ឧទាហរណ៍ ឪពុកម្តាយអាចជឿថា កូនស្រីរបស់ខ្លួន ដែលខ្សោយគំហើញ មិនអាចរៀនចេះឡើយ។ ប្រសិនបើពួកគាត់គិតបែបនោះ ពួកគាត់នឹងមិនបញ្ជូនកូនទៅសាលារៀនឡើយ។ ប៉ុន្តែប្រសិនបើពួកគាត់គិតថា កូនស្រីរបស់ពួកគាត់មានសិទ្ធិទទួលបានការអប់រំ ដូចកុមារដទៃទៀត ពួកគាត់នឹងគាំទ្រឱ្យនាងទៅរៀនជាមិនខាន។

នៅពេលដែលជនពិការទទួលរងឥរិយាបថអវិជ្ជមានមកលើពួកគាត់ ជារឿយៗ ពួកគាត់ខ្លួនឯងតែងតែគិតថា ខ្លួនជាមនុស្សដែលពុំមានតម្លៃ និងត្រូវការឱ្យគេជួយដែរ។ ពួកគាត់អាចខ្វះការឱ្យតម្លៃខ្លួនឯង និងជឿថា ពួកគាត់មិនអាចរៀនអ្វីថ្មីឡើយ។

នៅពេលដែលឥរិយាបថវិជ្ជមាន នោះជនពិការគិតថា ពួកគាត់ត្រូវបានគេឱ្យចូលរួម និងទទួលបានការស្វាគមន៍។ ពួកគាត់នឹងទទួលបានការប្រតិបត្តិយ៉ាងល្អ ដោយមិនគិតពីអាយុ ជាតិពន្ធ[2] ឬពិការភាពរបស់ពួកគាត់ឡើយ។ និយាយរួម ជនពិការនឹងទទួលបានការប្រតិបត្តិប្រកបដោយការគោរព និងសេចក្តីថ្លៃថ្នូរ។

[2] ជាតិពន្ធ គឺសំដៅទៅលើក្រុមមនុស្សដែលមានប្រវត្តិដូចគ្នា ដូចជា វប្បធម៌ ភាសា ជំនឿសាលនា ប្រពៃណី និងរបៀបរបបនៃការរស់នៅជាដើម។

# កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................។

|  |  |
| --- | --- |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

- ពាក្យពេចន៍អវិជ្ជមាន គឺជាពាក្យដែលរៀបរាប់ពីជនពិការថា ជនរងគ្រោះ ប៉ុន្តែវាក៏ជាពាក្យពេចន៍ដែលបន្ទោសដល់ជនពិការខ្លាចរអែង ឬខ្ពើមរអើមពួកគាត់ ឬបង្ហាញពីការស្អប់ពួកគាត់ជាដើម។
- ពាក្យពេចន៍វិជ្ជមាន គឺជាពាក្យដែលផ្តោតលើអ្វីដែលមនុស្សម្នាក់អាចធ្វើបាន។ ពួកគេចាត់ទុកជនពិការដូចជាមនុស្សដទៃទៀតដែរ ហើយពិការភាពរបស់ជនពិការ គឺគ្រាន់តែជាចំណុចមួយរបស់ពួកគាត់ប៉ុណ្ណោះ។ ពួកគេចាត់ទុកជនពិការថា មានភាពស្មើភាពគ្នា និងអាចធ្វើកិច្ចការបានជាច្រើន។

**សារគន្លឹះ:**

- ជនពិការនិយាយថា ឥរិយាបថអវិជ្ជមានចំពោះពិការភាព គឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗជាងគេដែលពួកគេជួបប្រទះ។
- ជនពិការចង់មានអារម្មណ៍ថា គេស្វាគមន៍ខ្លួន គេធ្វើល្អដាក់ខ្លួនដោយផ្តល់នូវការគោរព និងសេចក្តីថ្លៃថ្នូរ។
- វាជាការសំខាន់ដែលត្រូវប្រើប្រាស់ភាសាឱ្យបានសមរម្យនៅពេលដែលនិយាយអំពីជនពិការ។

### ៣.៣. ភាសាបង្ហាញពីការគោរពអំពីពិការភាព

| ប្រភេទនៃភាពខ្សោយ | ពាក្យដែលមិនគួរប្រើ | ពាក្យដែលសម្តែងការគោរព |
|---|---|---|
| **ភាពខ្សោយខាងរាងកាយ** | អាកាបាក់ | ពិការជើង |
| | អាកាបុត | ពិការដៃ |
| | អាខ្វិន | ពិការជើង |
| | អាដាច់ | ពិការជើងឬ ដៃ |
| | អាកាង៉ែរ | ពិការដៃ |
| | អាពៀច | ពិការជើង |
| | អាក្រង៉ែង | ពិការដៃ |
| | អាខ្វេ | ពិការជើងឬ ដៃ |
| | អាគម | ពិការខ្នង |
| | អាស្កន់ជាន់ | ពិការចលករខួរក្បាល |
| | អាប្រកាច់ | ពិការចលករខួរក្បាល ឬប្រកាច់ |
| **ភាពខ្សោយគំហើញ** | អាខ្វាក់ | ពិការភ្នែក |
| | អាងងឹត | ពិការក្នុងការមើល |
| | អាស្រឡេវ | ពិការភ្នែក |
| **ភាពខ្សោយខាងការស្តាប់** | អាគ | ពិការគ-ថ្លង់ |

| ប្រភេទនៃភាពខ្សោយ | ពាក្យដែលមិនគួរប្រើ | ពាក្យដែលសម្តែងការគោរព |
|---|---|---|
| | អាថ្លង់ | ពិការក្នុងការស្តាប់ |
| | អាតម្លង់ | ពិការក្នុងការស្តាប់ |
| | អាកាង្វរ | ពិការក្នុងការនិយាយ |
| | អាតាឡាន់ | ពិការក្នុងការនិយាយ |
| **ភាពខ្សោយខាងបញ្ញាស្មារតី** | អាឆ្កួត | ពិការខ្សោយសតិបញ្ញា |
| | អាឡប់ | |
| | អាភ្លើ | |
| | អាឆ្កួតជ្រូក | |
| | អាអត់គ្រប់ទឹក | |
| | អាគ្រាសក្រឡង | |
| | អាប្រសៃប្រសាទ | |
| | អាឡឺកឺ | |
| | អាតក់ឡក់ | |

### ៣.៤. គោលការណ៍ណែនាំ សម្រាប់និយាយជាមួយជនពិការ

ក. ហៅជនពិការចំឈ្មោះ និងលើកឡើងពីពិការភាពរបស់ជននោះ តែនៅពេលដែលវាពាក់ព័ន្ធជាមួយនឹងអ្វី ដែលអ្នកកំពុងគិត។ ឧទាហរណ៍ ៖ កុំសួរថា "តើអ្នកមានបញ្ហាអ្វី?" កុំលើកពីមនុស្សទូទៅ ឬប្រើប្រាស់ពាក្យពេចន៍ទូទៅ ដូចជា "ក្មេងស្រីជិះរទេះរុញ" ជាដើម។

ខ. និយាយដោយផ្ទាល់ទៅកាន់ជនពិការ មិនមែនទៅកាន់ជំនួយការ ឬសមាជិកគ្រួសាររបស់គាត់នោះទេ នៅពេលដែលអ្នកចង់និយាយទៅកាន់ជនពិការ។

គ. វាមិនថ្វីនោះទេ ក្នុងការប្រើពាក្យ ឬឃ្លា ដូចជា "ពិការ" "ពិការភាព" ឬ "ជនពិការ" ជាដើម នៅពេលនិយាយអំពីបញ្ហាពិការភាព។ សួរទៅជនពិការ ថាតើពាក្យណាដែលពួកគាត់ចង់ប្រើប្រាស់នៅពេលដែលពួកគាត់មានពិការភាព។

ឃ. នៅពេលនិយាយពីអ្នកដែលពុំមានពិការភាព វាមិនថ្វីនោះទេក្នុងការនិយាយ "អ្នកមិនពិការ"។ ប៉ុន្តែសូមកុំហៅពួកគាត់ថាជាមនុស្ស "ធម្មតា" ឬ "មានសុខភាពល្អ"។ ពាក្យពេចន៍ទាំងនេះអាចធ្វើឱ្យជនពិការមានអារម្មណ៍ថាពួកគាត់មានអ្វីមួយខុស ហើយពួកគាត់គឺជាមនុស្ស "ខុសធម្មតា"។

ង. ប្រើភាសាដែលសម្តែងពីការគោរព និងចៀសវាងប្រើប្រាស់ពាក្យដែលមិនសម្តែងពីការគោរព។

# កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

........................................................................................................................................។

**សង្ខេបពីការបង្ហាញការគោរព និងសេចក្តីថ្លៃថ្នូរ**

១. អ្វីដែលមនុស្សគិត(ឥរិយាបថ) កំណត់ពីរបៀបដែលមនុស្សធ្វើសកម្មភាព និងភាសាដែលពួកគាត់ប្រើប្រាស់។

២. ឥរិយាបថអវិជ្ជមាន គឺជាឧបសគ្គធំជាងគេដែលជនពិការជួបប្រទះ។

៣. ឥរិយាបថអវិជ្ជមានចំពោះជនពិការនឹងមានផលប៉ះពាល់មកលើការផ្តល់តម្លៃដល់ខ្លួនឯងរបស់ពួកគាត់ ហើយពួកគាត់នឹងចាប់ផ្តើមជឿថា ពួកគាត់ពុំមានតម្លៃ ហើយត្រូវការការគាំទ្រ។

៤. សូមកុំប្រើពាក្យអសុរស ប៉ុន្តែប្រើភាសាអព្យាក្រឹត ដូចពេលដែលអ្នកនិយាយពីអ្នកដែលមិនពិការដូច្នោះដែរ។

៥. និយាយទៅកាន់ជនពិការ ដោយចាត់ទុកគាត់ជាមនុស្ស ដោយសារតែពិការភាពគ្រាន់តែជាទិដ្ឋភាពមួយនៃជីវិតរបស់គាត់តែប៉ុណ្ណោះ។

៦. ប្រសិនបើអ្នកមិនដឹងពីអ្វីដែលសមស្រប សូមសួរទៅកាន់ជនពិការ។ ជានិច្ចកាលត្រូវប្រើពាក្យដែលផ្អែកទៅតាមការគោរព និងសេចក្តីថ្លៃថ្នូរ។

# ជំពូកទី៤

# ការប្រាស្រ័យទាក់ទង

# ជាមួយជនពិការ

# ជំពូកទី៤

# ការប្រាស្រ័យទាក់ទងជាមួយជនពិការ

## ៤.១. ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព

ការប្រាស្រ័យទាក់ទង គឺជាដំណើរការមួយសម្រាប់ឈានទៅដល់ការយោគយល់គ្នាទៅវិញទៅមក ដោយអ្នកចូលរួមត្រូវចែករំលែកព័ត៌មាន គំនិត និងអារម្មណ៍។ វាគឺជាដំណើរការទ្វេទិស។

ការប្រាស្រ័យទាក់ទងអាចកើតឡើងតាមបែបផែនច្រើនយ៉ាង ដូចជា ៖

- ការប្រើពាក្យសម្ដី ឬការនិយាយ
- ការប្រើសញ្ញា ឬការប្រើពាក្យសម្ដី ដូចជា កាយវិការ ទឹកមុខ ទំនាក់ទំនងតាមកែវភ្នែក។ល។
- ការសរសេរ

នៅពេលនិយាយទៅកាន់មនុស្សម្នាក់ដែលមានភាពខ្សោយអ្វីមួយ ពេលខ្លះគេមានការលំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយពួកគាត់។ ប៉ុន្តែ នៅពេលដែលការប្រាស្រ័យទាក់ទងតាមបែបផែនមួយហាក់បីដូចជាពិបាក គេនៅតែអាចរិះរកវិធីផ្សេងទៀតសម្រាប់ធ្វើការប្រាស្រ័យទាក់ទង។ ឧទាហរណ៍ ប្រសិនបើការប្រាស័យទាក់ទងដោយការសរសេរ និងការប្រើសញ្ញាពុំមានប្រសិទ្ធភាពសម្រាប់អ្នកដែលខ្សោយខាងគំហើញ នោះគេអាចប្រើសារជាពាក្យសម្ដីឬសម្លេងបាន។ យើងអាចប្រើប្រាស់សារជាលាយល័ក្ខណ៍អក្សរគំនូរ ឬកាយវិការអាចមានប្រសិទ្ធភាពល្អ ចំពោះជនពិការគ ថ្លង់។

## កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................។

**សារគន្លឹះ:**

- ការប្រាស្រ័យទាក់ទង គឺជាដំណើរការទ្វេទិស ហើយក៏តម្រូវឲ្យមានការស្ដាប់ផងដែរ។
- មានវិធី៣យ៉ាង សម្រាប់ធ្វើការប្រាស្រ័យទាក់ទង ៖ ដោយការប្រើពាក្យសម្ដីឬនិយាយ ការមិនប្រើពាក្យសម្ដីឬសញ្ញា និងការសរសេរ។
- ត្រូវមានភាពច្នៃប្រឌិត ប្រសិនបើរបៀបប្រាស្រ័យទាក់ទងមួយពុំមានប្រសិទ្ធភាពទេ សូមសាកល្បងរបៀបមួយផ្សេងទៀត។

## ៤.២. របៀបធ្វើការប្រាស្រ័យទាក់ទងជាមួយជនពិការគ ថ្លង់ ឬអ្នកដែលខ្សោយខាងការស្ដាប់

ដំបូន្មានមួយចំនួនសម្រាប់ប្រាស្រ័យទាក់ទងជាមួយនឹងជនពិការគ-ថ្លង់ ឬអ្នកដែលពិបាកស្ដាប់ ៖



- ទាក់ទាញការយកចិត្តទុកដាក់របស់ជនពិការគ-ថ្លង់ ប្រសិនបើគាត់មិនប្រតិកម្មតបទេនោះ សូមប៉ះដៃ ឬស្មារបស់គាត់ថ្នមៗ ឬបក់ដៃហៅគាត់
- សួរថាតើគាត់ចង់បានការប្រាស្រ័យទាក់ទងដោយរបៀបណា
- ឈរបែរមុខទៅរកគាត់។ អ្នកដែលមានពិការភាពខាងការស្ដាប់ចង់ឃើញមុខរបស់អ្នក ដើម្បីពួកគាត់អាចអាន(មើល)បបូរមាត់របស់អ្នក និងមើលទឹកមុខរបស់អ្នក។ ឈរត្រឹមកម្ពស់ស្មើគ្នានឹងគាត់ ឧទាហរណ៍ ៖ សូមអង្គុយចុះ ប្រសិនបើគាត់អង្គុយ។ កុំដាក់ដៃរបស់អ្នកបាំងមុខរបស់អ្នក
- ផ្លាស់ទៅកន្លែងស្ងាត់ ដើម្បីកុំឱ្យមានសំឡេងរំខាន ឬមានសំឡេងរំខានតិចតួច
- ឈរក្បែរគាត់ ដើម្បីឱ្យអ្នកដែលពិបាកស្ដាប់ អាចស្ដាប់ឮអ្នកនិយាយឱ្យបានប្រសើរបំផុត
- មានភ្លើងបំភ្លឺគ្រប់គ្រាន់ ដើម្បីឱ្យគាត់អាចមើលឃើញអ្នកបានច្បាស់
- និយាយច្បាស់ៗ និងក្នុងកម្រិតសំឡេងធម្មតា(សូមកុំស្រែក)
- សួរថា តើគាត់យល់ពីអ្វីដែលអ្នកបាននិយាយដែរឬទេ ដូចជាឱ្យគាត់ផ្ដល់ព័ត៌មានត្រឡប់ឡប់
- និយាយសារសំខាន់ៗឡើងវិញ ដូចជា សរសេរសារទាំងនេះ ជាដើម
- ប្រើប្រាស់ទឹកមុខ និងកាយវិការ ដើម្បីគាំទ្រដល់អ្វីដែលអ្នកនិយាយ
- និយាយទៅគាត់ដោយផ្ទាល់។ សូមកុំនិយាយទៅកាន់សមាជិកគ្រួសារ ឬអ្នកបកប្រែ
- នៅក្នុងអគាររបស់អ្នក សូមដាក់សញ្ញាឱ្យបានច្បាស់ ដើម្បីជួយឱ្យជនពិការគ-ថ្លង់និងអ្នកពិបាកស្ដាប់ដឹងពីកន្លែងដែលត្រូវទៅ
- ផ្ដល់ព័ត៌មានជាលាយល័ក្ខណ៍អក្សរ ប្រសិនបើគាត់អាចអាន និងសរសេរបាន។ ត្រៀមប៊ិច និងក្រដាស ក្នុងករណីដែលអ្នកចាំបាច់ត្រូវប្រាស្រ័យទាក់ទងដោយសរសេរ

## កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

.........................................................................................................................................។

## ៤.៣. របៀបធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដែលមានពិការភាពខាងសតិបញ្ញា

ដំបូន្មានមួយចំនួនសម្រាប់ប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដែលមានពិការភាពខាងសតិបញ្ញា ៖

- ត្រូវបង្ហាញនូវភាពជាក់ស្តែង
- ចំណាយពេលតាមសម្រួល ហើយបង្កើតនូវការជឿទុកចិត្តគ្នាសិន ដើម្បីឱ្យគាត់មានអារម្មណ៍កក់ក្តៅ ជាមួយអ្នក
- និយាយឱ្យបានច្បាស់ៗ និងប្រើប្រាស់ប្រយោគខ្លី និងពាក្យពេចន៍ងាយៗ
- និយាយឡើងវិញពីអ្វីដែលអ្នកបាននិយាយ ឬប្រើពាក្យពេចន៍ផ្សេង ដើម្បីបញ្ជាក់ពីអ្វីដែលអ្នកបាននិយាយ
- ប្រើប្រាស់រូបភាព
- កុំប្រើសំឡេងដូចក្មេង ឬនិយាយបំផ្លើស
- ប្រើឯកសារដែលងាយស្រួលអាន អមដោយសារងាយៗ និងប្រយោគខ្លីៗ
- រកកន្លែងស្ងាត់ សម្រាប់និយាយ
- ប្រើកាយវិការ និងទឹកមុខ ឧទាហរណ៍ ធ្វើទឹកមុខសោកសៅ នៅពេលដែលអ្នកកំពុងនិយាយ អ្វីមួយ ដែលមិនសប្បាយចិត្ត
- បញ្ជាក់ជាមួយគាត់ថាតើគាត់យល់ពីអ្វីដែលអ្នកកំពុងនិយាយដែរឬទេ។

## កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

.............................................................................................................................................
.............................................................................................................................................
.............................................................................................................................................
.............................................................................................................................................
.............................................................................................................................................
.............................................................................................................................................
.............................................................................................................................................
.............................................................................................................................................
.............................................................................................................................................
.............................................................................................................................................
.............................................................................................................................................
.............................................................................................................................................
.............................................................................................................................................
.............................................................................................................................................
......................................................................................................................................... ។

## ៤.៤. របៀបធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដែលខ្សោយគំហើញ

ដំបូន្មានមួយចំនួនសម្រាប់ប្រាស្រ័យទាក់ទងទៅកាន់អ្នកដែលខ្សោយខាងគំហើញ ៖



- ណែនាំខ្លួនអ្នក ដើម្បីឱ្យអ្នកដែលខ្សោយខាងគំហើញស្គាល់ថាអ្នកជាអ្នកណា
- ប្រាប់គាត់ ប្រសិនបើអ្នកទៅឆ្ងាយពីគាត់។ សូមកុំចាកចេញពីគាត់ដោយមិនបានប្រាប់គាត់ថាអ្នកនឹងចាកចេញពីគាត់។
- រៀបរាប់ពីទីកន្លែងដែលអ្នកកំពុងនៅ និងអ្វីដែលអ្នកឃើញឱ្យគាត់ដឹង
- ត្រូវរៀបរាប់ឱ្យបានជាក់លាក់។ និយាយថា"តុនៅចំពីមុខអ្នក" មិនមែន "តុនៅទីនេះ" នោះទេ។
- នៅពេលដែលអ្នកស្ថិតនៅក្នុងក្រុម សូមប្រាប់ពួកគាត់ពីអ្នកដែលកំពុងមានវត្តមាននៅក្នុងក្រុម
- សូមកុំផ្លាស់ប្តូរទីតាំងរបស់វត្ថុនានា ឬទុកអ្វីមួយនៅលើផ្លូវដែលអាចធ្វើឱ្យគេដើរជាន់
- នៅពេលដែលអ្នកនិយាយក្នុងក្រុម សូមប្រើប្រាស់ឈ្មោះរបស់គាត់នៅពេលដែលអ្នកចង់និយាយទៅគាត់
- ជានិច្ចកាល សូមនិយាយដោយផ្ទាល់ទៅគាត់។ សូមកុំប្រើមនុស្សទីពីរឱ្យឆ្លើយសំណួររបស់អ្នក
- និយាយបែបធម្មតា និងច្បាស់ៗ។ អ្នកមិនចាំបាច់ស្រែកនោះទេ
- ចៀសវាងកន្លែងដែលមានសំឡេងរំខាន ដើម្បីឱ្យគាត់អាចស្តាប់អ្នកបានច្បាស់
- ជានិច្ចកាល ត្រូវសួរសិនថាតើគាត់ចង់ឱ្យគេជួយដែរឬទេ។ សូមកុំជួយអ្នកណាម្នាក់ដោយមិនបានសួរគាត់ជាមុន
- សម្រាប់អ្នកដែលខ្សោយខាងគំហើញ សូមប្រើប្រាស់សញ្ញា និងឯកសារដែលច្បាស់ៗ អាចជាអក្សរធំៗ ឬ អក្សរដែលអ្នកអាចស្ទាបដឹងបាន
- សម្រាប់អ្នកដែលពិការភ្នែក ហើយអាចអានអក្សរស្ទាបបាន អ្នកអាចផ្តល់ព័ត៌មានលាយលក្ខណ៍អក្សរដោយប្រើអក្សរស្ទាប
- បច្ចេកទេសក្នុងការនាំផ្លូវអ្នកពិការគំហើញ ដូចជាការដើរទន្ទឹមគាត់ក្នុងទីធ្លាទូលាយ និងដើរពីមុខគាត់ក្នុងទីធ្លាចង្អៀតក្នុងករណីឡើងជណ្តើរ ឬចូលជណ្តើរយន្តត្រូវពន្យល់គាត់ឱ្យបានច្បាស់ និង និយាយមួយៗរៀបរាប់ប្រាប់គាត់។

# កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

…………………………………………………………………………………………………… ។

## សង្ខេបជំពូកទី ៤

- ការប្រាស្រ័យទាក់ទង គឺជាដំណើរការ ដើម្បីឱ្យមានការយល់គ្នាទៅវិញទៅមក ជាមួយនឹងអ្នកចូលរួម ដែលធ្វើការចែករំលែកព័ត៌មាន គំនិត និងអារម្មណ៍នានា។
- ការប្រាស្រ័យទាក់ទង អាចកើតឡើងតាមបែបផែនចំនួន ៣ ដោយប្រើពាក្យសម្ដី មិនប្រើពាក្យសម្ដី និងជាលាយលក្ខណ៍អក្សរ។
- មានអង្គការសង្គមស៊ីវិល នៅក្នុងប្រទេសកម្ពុជា ដែលមានជំនាញខ្ពស់ ខាងពិការភាពប្រភេទខុសៗ គ្នា។ អង្គការទាំងនេះអាចផ្ដល់ព័ត៌មានបន្ថែមបាន។
- អ្វីដែលសំខាន់ គឺត្រូវប្រុងប្រយ័ត្ន នៅពេលដែលយើងប្រតិកម្មតបចំពោះជនពិការ។ គ្រាន់តែ ដោយសារតែការប្រាស្រ័យទាក់ទងជារឿងពិបាក មិនមែនមានន័យថា គេមិនអាចធ្វើការប្រាស្រ័យទាក់ទងនោះទេ។ សូមចាំថា ការប្រាស្រ័យទាក់ទង គឺជាដំណើរការទ្វេទិស។

# ជំពូកទី៥
# ការបង្កើតបរិស្ថានដែលគ្មានឧបសគ្គរាំងដល់ជនពិការ

# ថ្ងៃទី៣

## ជំពូកទី៥
## ការបង្កើតបរិស្ថានដែលគ្មានឧបសគ្គរាំងដល់ជនពិការ

### ៥.១. ការរំលឹកមេរៀននៅថ្ងៃទី២

តើអ្នករៀនបានអ្វីខ្លះនៅថ្ងៃទី២ ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

..............................................................................................................................។

### ៥.២. អត្ថន័យនៃការបង្កភាពងាយស្រួលក្នុងការចេញ ចូលសម្រាប់ជនពិការ

និយមន័យនៃការបង្កភាពងាយស្រួលក្នុងការចេញចូលសម្រាប់ជនពិការ មានន័យថា ជនពិការអាច ៖

- ផ្លាស់ទីដោយសេរី ដោយពុំមានឧបសគ្គ
- ផ្លាស់ទី ដោយម្ចាស់ការខ្លួនឯង(ដោយពុំមានជំនួយផ្ទាល់ពីអ្នកដទៃ)
- ផ្លាស់ទី ដោយមានទំនុកចិត្ត និងប្រកបដោយការគោរព

មនុស្សផ្សេងគ្នា អាចមានបទពិសោធន៍ខុសៗគ្នា ទោះជាស្ថិតក្នុងបរិស្ថានតែមួយ។ បរិស្ថានដែលសាមញ្ញសម្រាប់មនុស្សម្នាក់ អាចជាការលំបាកសម្រាប់មនុស្សម្នាក់ផ្សេងទៀត។ ជាការសំខាន់ណាស់ដែលគេត្រូវកែសម្រួលបរិស្ថានទាំងនេះ ដើម្បីផ្តល់ភាពងាយស្រួលដល់មនុស្សគ្រប់គ្នាអាចប្រើប្រាស់បាន។

**សារគន្លឹះ**

- ការបង្កភាពងាយស្រួលក្នុងការចេញចូល មានន័យថា ជនពិការអាច ៖
  - ផ្លាស់ទី ដោយម្ចាស់ការខ្លួនឯង(ដោយពុំមានជំនួយផ្ទាល់ពីអ្នកដទៃ)
  - ផ្លាស់ទី ដោយមានទំនុកចិត្ត និងប្រកបដោយការគោរព
- តម្រូវការនៃការបង្កភាពងាយស្រួលក្នុងការចេញចូល មានការប្រែប្រួលខុសៗគ្នាតាមមនុស្សម្នាក់ៗ
- ការផ្តោតការយកចិត្តទុកដាក់លើការបង្កភាពងាយស្រួលក្នុងការចេញចូលនៅដំណាក់កាលរៀបចំផែនការនៃគម្រោងសាងសង់ គឺមានភាពងាយស្រួលជាង និងចំណាយថវិកា ឬពេលវេលាតិចជាងសំណង់សាងសង់រួចដែលត្រូវកែសម្រួលតាមក្រោយ។

**ឧទាហរណ៍ ÷ មិនងាយស្រួលចេញចូល ឬប្រើប្រាស់**



ហេតុអ្វីបានជាមិនងាយស្រួលចេញចូល ឬប្រើប្រាស់?

- មូលហេតុ ៖
  - ជម្រាលចោតពេក
  - ពុំមានបង្កាន់ដៃ
  - ផ្ទៃខាងលើមិនរាបស្មើ
- លទ្ធផល ៖
  - ពុំមានអ្នកណាអាចប្រើបាន
  - មានគ្រោះថ្នាក់

**ឧទាហរណ៍ ÷ ងាយស្រួលចេញចូល ឬប្រើប្រាស់**



ហេតុអ្វីបានជាងាយស្រួលចេញចូល ឬប្រើប្រាស់?

- មូលហេតុ ៖
  - ជម្រាលមានចំណោតសមស្រប
  - មានបង្កាន់ដៃ
  - ផ្ទៃរាបស្មើ
  - សញ្ញាសម្គាល់ច្បាស់លាស់
- លទ្ធផល ៖
  - អ្នកណាៗក៏អាចប្រើបាន

| ប្រភេទ | តម្រូវការពាក់ព័ន្ធនឹងភាពងាយស្រួលក្នុងការចេញចូល |
|---|---|
| **អ្នកដែលខ្សោយខាងគំហើញ**<br> | • ភ្លើងបំភ្លឺឱ្យបានគ្រប់គ្រាន់សម្រាប់អ្នកដែលខ្សោយខាងគំហើញ<br>• មានសញ្ញាសម្គាល់ សម្រាប់កំណត់បង្ហាញ<br>• មានបង្កាន់ដៃ ដែលជាប់ និងមានសុវត្ថិភាព<br>• មានសញ្ញា ដូចជា អក្សរស្ទាប អក្សរផុស និង/ឬអក្សរធំៗ<br>• ច្រកផ្លូវពុំមានវត្ថុ ឬរបស់របរនៅបាំង ដើម្បីកុំឱ្យអ្នកដែលខ្សោយខាងគំហើញជំពប់ |
| **អ្នកដែលខ្សោយខាងស្តាប់ និង/ឬនិយាយ**<br><br> | • ការផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ<br>• ភ្លើងបំភ្លឺពុំមានចំណាំង ដើម្បីងាយស្រួលអានតាមបបូរមាត់ និងងាយស្រួលធ្វើតាមភាសាសញ្ញា<br>• មានការប្រើសម្លេងបានល្អ នៅក្នុងបន្ទប់ប្រជុំ<br>• ប្រើវិធីសាស្ត្រនានាសម្រាប់ជាជម្រើស ក្នុងការប្រាស្រ័យទាក់ទងនៅទីសាធារណៈ ដូចជា ការសរសេរអក្សរធំៗលើក្រដាស ជាដើម |
| **អ្នកដែលខ្សោយខាងបញ្ញា និង/ឬសុខភាពផ្លូវចិត្ត**<br><br> | • មានសញ្ញាច្បាស់លាស់ និងបង្ហាញនៅច្រើនកន្លែង<br>• កន្លែងស្ងាត់សម្រាប់សួរសំណួរ<br>• ឯកសារងាយស្រួលអាន ៖ សារអប់រំងាយៗ និងច្បាស់លាស់ អមដោយរូបភាព |
| **អ្នកដែលខ្សោយខាងកាយសម្បទា(ពិបាកដើរ)**<br> | • មានផ្លូវដើរ ជម្រាល និងច្រកទ្វារធំៗ ដើម្បីផ្តល់លទ្ធភាពឱ្យមនុស្សដែលប្រើរទេះរុញងាយស្រួលផ្លាស់ទី<br>• ទុកដាក់វត្ថុនានា ដែលអាចឈោងដល់បានពីកន្លែងអង្គុយ<br>• បង្គន់ និងកន្លែងលាងដៃ ងាយស្រួលប្រើប្រាស់សម្រាប់ជនពិការ<br>• បង្កាន់ដៃជាប់ និងមានសុវត្ថិភាព<br>• មានកន្លែងអង្គុយ ឬកៅអីវែង(បង់) ដើម្បីឱ្យអ្នកដែលមានការពិបាកក្នុងការដើរអាចសម្រាកបាន |
| **អ្នកដែលខ្សោយខាងកាយសម្បទា(ពិបាកប្រើដៃ)**<br> | • ប្រើប្រាស់ដៃទ្វារប្រភេទទ្រវែង ជំនួសឱ្យដៃទ្វារមូល<br>• ពង្រីកប្រវែងដៃអណ្តូងស្នប់ទឹក ដើម្បីងាយស្រួលសប់ទឹក<br>• បំពាក់បង្កាន់ដៃបន្ទប់ទឹក ផ្លូវចេញ ចូល... ដើម្បីឱ្យពួកគេងាយស្រួលកាន់ ឬផ្អែកសម្រាប់អ្នកដែលពិបាកប្រើដៃ |

## ៥.៣. ការពិនិត្យលើភាពងាយស្រួលក្នុងការចេញចូល

| សំណួរ | លទ្ធផលរកឃើញ (បាទចាស/ទេ/ មិនពាក់ព័ន្ធ) |
|---|---|
| **១. ខាងក្រៅ** | |
| • តើផ្លូវដើរមានសភាពរាបស្មើ និងជាប់គ្នារហូតដែរឬទេ? | |
| • តើផ្លូវដើរមានទំហំធំទូលាយគ្រប់គ្រាន់ដែរឬទេ(១៥០០មីលីម៉ែត្រ)? | |
| • តើផ្លូវដើរមិនរអិល និងមិនមានឧបសគ្គបាំងដែរឬទេ? | |
| • តើច្រកចូលអគារងាយស្រួលចេញ ចូលសម្រាប់អ្នកប្រើរទេះរុញដែរឬទេ? | |
| **២. ច្រកផ្លូវ** | |
| • តើច្រកទាំងនេះមិនមានអ្វីមកបាំងមែនទេ? | |
| • តើច្រកសាធារណៈដែលមិនសូវមានគេធ្វើដំណើរ មានទំហំយ៉ាងហោចណាស់១៥០០មីលីម៉ែត្រឬ? | |
| • តើផ្ទៃរបស់ច្រកផ្លូវមានលក្ខណៈរាបស្មើ និងមិនរអិលដែរឬទេ? | |
| • តើច្រកផ្លូវសម្រាប់ធ្វើដំណើរងាយស្រួលសម្គាល់ដែរឬទេ?  | |
| **៣. ទ្វារ** | |
| • តើទ្វារមានទទឹងយ៉ាងហោចណាស់ ៨០០មីលីម៉ែត្រដែរឬទេ? | |
| • តើអ្នកប្រើប្រាស់ត្រូវឆ្លងកាត់ចំណោតខ្ពស់ជាង២០មីលីម៉ែត្រឬ? | |
| • តើទ្វារងាយស្រួលបើក ដោយប្រើដៃម្ខាងឬទេ? | |
| • តើទ្វារមានទំហំយ៉ាងហោចណាស់ ១៥០០មីលីម៉ែត្រx១៨០០មីលីម៉ែត្រ ដើម្បីឱ្យអ្នកប្រើប្រាស់រទេះរុញងាយស្រួលបើកទ្វារដែរឬទេ? | |

| **សំណួរ** | **លទ្ធផលរកឃើញ** (បាទចាស/ទេ/ មិនពាក់ព័ន្ធ) |
|---|---|
|  | |
| • តើទ្វារងាយស្រួលបើកដែរឬទេ ? | |
| **៤. ជម្រាល ជណ្តើរ និងបង្កាន់ដៃ** | |
| • តើនៅជាន់តែមួយ ផ្លូវដើរពុំមានការផ្លាស់ប្តូរកម្ពស់ ឬជណ្តើរមែនទេ ? | |
| • តើចំណោតរបស់ជម្រាលដែលកំពុងគ្រោងទុក ដែលមានស្រាប់ ឬជម្រាលសម្រាប់ទប់មានកម្ពស់អតិបរមា ១:១២ ឬ ?   | |
| • តើជម្រាលមានទទឹងយ៉ាងហោចណាស់ ១០០០មីលីម៉ែត្រ ឬ ? | |
| • តើបង្កាន់ដៃ ត្រូវបានបំពាក់នៅកម្ពស់ចន្លោះពី៨០០មីលីម៉ែត្រ ទៅ៩០០មីលីម៉ែត្រ ដើម្បីបង្កើនសុវត្ថិភាពនៅពេលប្រើប្រាស់ជម្រាល និងជណ្តើរដែរឬទេ ? | |
| • តើជណ្តើរ និងជម្រាលងាយស្រួលសម្គាល់ដែរឬទេ ?  | |

| សំណួរ | លទ្ធផលរកឃើញ (បាទចាស/ទេ/ មិនពាក់ព័ន្ធ) |
|---|---|
| **៥. កន្លែងរង់ចាំ និងសម្ភាររូបវ័ន្តពាក់ព័ន្ធ** | |
| • តើមានផ្តល់កន្លែងឈប់សម្រាករៀងរាល់ ២០ម៉ែត្រម្តងដែរឬទេ ? | |
| • តើកន្លែងសម្រាកមានទំហំធំគ្រប់គ្រាន់ សម្រាប់អ្នកប្រើប្រាស់រទេះ ដែរឬទេ ? | |
| • តើកៅអីសាធារណៈមានកម្ពស់ចន្លោះពី៤៥០មីលីម៉ែត្រ ទៅ៥០០មីលីម៉ែត្រ ហើយតុមានកម្ពស់ចន្លោះពី៧៥០មីលីម៉ែត្រ ទៅ៨០០មីលីម៉ែត្រ ដោយមានចន្លោះសម្រាប់ដាក់ជង្គង់មានកម្ពស់យ៉ាងហោចណាស់៧០០មីលីម៉ែត្រ និងជម្រៅ៦០០មីលីម៉ែត្រ ដែរឬទេ ? | |
| **៦. បង្គន់ បន្ទប់ទឹក** | |
| • តើមានបង្គន់ងាយស្រួលប្រើប្រាស់ ដោយជនពិការដែរឬទេ ?   How a wheelchair user transfer himself from his chair to the toilet seat | |
| • តើបង្គន់ដែលអាចប្រើបានដោយជនពិការ មានសញ្ញាសម្គាល់ដែរឬទេ ? | |
| **៧. ស្លាកសញ្ញា** | |
| • តើកន្លែង និងសម្ភាររូបវ័ន្តដែលអាចប្រើប្រាស់បានដោយជនពិការ មានសញ្ញាបង្ហាញដែរឬទេ ? | |
| • តើមានការបង្ហាញពីទីតាំងរបស់កន្លែង និងសម្ភាររូបវ័ន្ត ដែលអាចប្រើប្រាស់បានដោយជនពិការដែរឬទេ ? | |
| • តើផែនទី ផ្ទាំងព័ត៌មាន និងស្លាកសញ្ញាដែលភ្ជាប់ទៅនឹងជញ្ជាំងទាំងអស់មានកម្ពស់សមស្របចន្លោះពី៩០០មីលីម៉ែត្រ ទៅ១៨០០មីលីម៉ែត្រដែរឬទេ ? | |
| • តើព័ត៌មានសំខាន់ៗអំពីសញ្ញាត្រូវបានបំពេញបន្ថែមដោយអក្សរផុស ឬអក្សរ | |

| សំណួរ | លទ្ធផលរកឃើញ (បាទចាស/ទេ/ មិនពាក់ព័ន្ធ) |
|---|---|
| ស្ទាបដែរឬទេ ? | |
| • តើសញ្ញាមានភាពច្បាស់លាស់ និងងាយស្រួលអានដែរឬទេ ?   | |
| **៩. ប្រព័ន្ធពេលមានអាសន្ន** | |
| • តើច្រកផ្លូវអាសន្នអាចកំណត់ដឹងបាន ដោយអ្នកដែលខ្សោយខាងគំហើញដែរឬទេ ? | |
| • តើក្នុងស្ថានភាពអាសន្ន អ្នកដែលខ្សោយខាងការស្តាប់អាចដឹងបានដែរឬទេ ? | |



**វាស់ទទឹងផ្លូវចូល**



**វាស់ទទឹងរទេះ**

## ៥.៤. ដំណោះស្រាយជាក់ស្ដែង ដើម្បីបង្កើនភាពងាយស្រួលក្នុងការចេញចូល

| ឧបសគ្គ | ដំណោះស្រាយ | អ្នកចាត់វិធានការ | ចំណាយ (ខ្ពស់ មធ្យម ទាប) |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

.......................................................................................................................................។

**សង្ខេបអំពីការបង្កភាពងាយស្រួលក្នុងការចេញចូលដោយពុំមានឧបសគ្គ**

១. ភាពងាយស្រួលចេញចូលរូបវ័ន្ត គឺពាក់ព័ន្ធជាមួយនឹងការផ្លាស់ទីដោយសេរីដោយគ្មានឧបសគ្គ ដោយម្ចាស់ការខ្លួនឯង និងប្រកបដោយទំនុកចិត្ត និងការគោរព។
២. តម្រូវការខាងភាពងាយស្រួលចេញចូលមានលក្ខណៈផ្សេងៗពីគ្នាទៅតាមមនុស្សម្នាក់ៗ។
៣. ការបង្កភាពងាយស្រួលក្នុងការចេញចូល ផ្តល់ប្រយោជន៍មិនត្រឹមតែដល់ជនពិការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ប្រយោជន៍ដល់មនុស្សជាច្រើនទៀតផង។
៤. សូមពិចារណាលើការបង្កភាពងាយស្រួលក្នុងការចេញចូល នៅដំណាក់កាលរៀបចំប្លង់អគារ ដើម្បីបញ្ចៀសការចំណាយលើការជួសជុល ឬការកែសម្រួលនៅពេលក្រោយ។
៥. ការអនុវត្តសាកល្បងអំពីការបង្កភាពងាយស្រួលក្នុងការចេញចូលតាមវិធីសាស្ត្រសាមញ្ញ និង តាមបែបចូលរួម បង្ហាញឱ្យឃើញពីឧបសគ្គដែលត្រូវដោះស្រាយបន្ទាន់ជាងគេនៅក្នុងអគារ
៦. ដំណោះស្រាយដែលអាចអនុវត្តបាន មិនមែនសុទ្ធតែត្រូវការចំណាយខ្ពស់រហូតនោះទេ។
៧. គ្រប់គ្នាអាចរួមចំណែកបង្កភាពងាយស្រួលក្នុងការចេញចូលបាន។



រូបភាពដកស្រង់ចេញពី ៖

http://www.apcdfoundation.org/?q=content/apcdjaifs-training-disability-awarenessadvocacy-cambodia-3-4-july-2014

# ជំពូកទី៦
# ការធានាឱ្យមានការចូលរួម
# យ៉ាងសកម្ម

# ជំពូកទី៦
# ការធានាឱ្យមានការចូលរួមយ៉ាងសកម្ម

## ៦.១. រៀបចំកិច្ចប្រជុំពិគ្រោះយោបល់

| |
|---|
| *"ពុំមានអ្វីសម្រាប់យើង ដោយគ្មានការចូលរួមពីយើងឡើយ"* |

**ការចូលរួម** មានន័យថា មនុស្សម្នាក់ៗអាចចូលរួមក្នុងសកម្មភាពអ្វីមួយ ឬចែករំលែកអ្វីមួយបាន។ ពួកគេបង្ហាញពីការយល់ឃើញរបស់ខ្លួន និងអាចមានឥទ្ធិពលលើការសម្រេចចិត្តនានា។ ការចូលរួមមិនមែនត្រឹមតែមានវត្តមានប៉ុណ្ណោះទេ ការចូលរួមមានន័យថា ពួកគេទទួលបានការស្វាគមន៍ និងទទួលបានការផ្តល់ភាពអង់អាចឱ្យចូលរួមយ៉ាងសកម្ម និងប្រកបដោយអត្ថន័យ។

ជនពិការអាចចូលរួម តាមបែបផែនផ្សេងៗគ្នា ៖

- ចូលរួម ក្នុងការរៀបចំផែនការ និងកម្មវិធីនានា
- ទទួលបានប្រយោជន៍ពីកម្មវិធី និងសេវានានា
- ចូលរួមក្នុងការងារគ្រប់គ្រង និងដឹកនាំ

ជនពិការ គឺជាសមាជិករបស់សង្គម និងជាសមាជិករបស់សហគមន៍ដែលពួកគេកំពុងរស់នៅ។ ពួកគេគួរអាចចូលទៅកាន់គ្លីនិកឬមណ្ឌលសុខភាព សាលារៀន និងចាប់ផ្តើមប្រកបរបរអាជីវកម្មដោយស្មើភាពគ្នា ដូចប្រជាពលរដ្ឋដទៃផងដែរ។ ផែនការនានា ដូចជា ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌ នឹងមានឥទ្ធិពលដោយផ្ទាល់ ឬប្រយោលមកលើការរស់នៅរបស់ជនពិការ ដូច្នេះ ជនពិការគួរត្រូវបាននិយាយដោយខ្លួនឯង និងចែករំលែកគំនិតយោបល់អំពីអ្វីដែលពួកគេចង់ធ្វើ និងមិនចង់ធ្វើ។ ក្នុងចលនាពិការភាព ពាក្យស្លោកខាងក្រោមត្រូវបានប្រើប្រាស់ ដើម្បីរៀបរាប់ពីចំណុចនេះ ៖ "ពុំមានអ្វីសម្រាប់យើង ដោយគ្មានការចូលរួមពីយើងឡើយ"។ **"ពុំមានអ្វីសម្រាប់យើង ដោយគ្មានការចូលរួមពីយើងឡើយ" មានន័យថាជនពិការអាចនិយាយ និងធ្វើការសម្រេចចិត្តដោយខ្លួនឯង** អំពីបញ្ហានានា ដែលមានផលប៉ះពាល់មកលើពួកគេ។

**សារគន្លឹះ**
- ជនពិការ គឺជាប្រជាពលរដ្ឋដូចគេដូចឯងដែរ ដូច្នេះផែនការ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាលមានឥទ្ធិពលលើពួកគេ។
- ជនពិការត្រូវការភាពអង់អាច ដើម្បីហ៊ាននិយាយ និងសម្រេចចិត្តសម្រាប់ខ្លួនឯង។
- ដើម្បីឱ្យជនពិការអាចចូលរួមឱ្យបានសកម្មចាំបាច់ត្រូវមានការត្រៀមរៀបចំមុនកិច្ចប្រជុំ។
- ប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ឬត្រួតពិនិត្យ ដើម្បីរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ដែលមានការចូលរួម។

## បញ្ជីផ្ទៀងផ្ទាត់សម្រាប់កិច្ចប្រជុំ និងព្រឹត្តិការណ៍ដែលជនពិការអាចចូលរួមបាន

- **គោលដៅ** ៖ រៀបចំកិច្ចប្រជុំ និងព្រឹត្តិការណ៍នានាដែលអាចឱ្យជនពិការអាចចូលរួមបាន។
- **លទ្ធផលរំពឹងទុក** ៖ ជនពិការអាចចូលរួមក្នុងកិច្ចប្រជុំ និងព្រឹត្តិការណ៍នានា ដែលបានរៀបចំឡើង។
- **គោលការណ៍ណែនាំ** ៖ ការបង្កភាពងាយស្រួលសម្រាប់ជនពិការ និងការរៀបចំ ៖
  - អំពីការរៀបចំទីកន្លែង
  - តើគេនឹងទៅដល់កន្លែងរៀបចំព្រឹត្តិការណ៍ ដោយរបៀបណា?
  - តើគេគេនឹងអាចចូលរួម នៅក្នុងព្រឹត្តិការណ៍នេះបាន ដោយរបៀបណា?

ជនពិការ គឺជាអ្នកជំនាញផ្នែកបង្កភាពងាយស្រួលសម្រាប់ជនពិការ អង្គការជនពិការនៅមូលដ្ឋានអាចជួយអ្នកក្នុងការរៀបចំកិច្ចប្រជុំ ដែលជនពិការអាចចូលរួមបាន។

**ក). ការអញ្ជើញជនពិការក្នុងសហគមន៍** ៖ **តើការកំណត់ និងការអញ្ជើញជនពិការត្រូវបានធ្វើឡើងយ៉ាងដូចម្តេច?**

| លរ | ចំណុចដែលត្រូវត្រួតពិនិត្យ | បាន/ចាស | ទេ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១. | តើជនពិការ ឬអង្គការជនពិការត្រូវបានអញ្ជើញ ដូចជាអង្គការផ្សេងៗទៀតដែរឬទេ? | | | |
| ២. | តើការអញ្ជើញធ្វើឡើងក្នុងទម្រង់ផ្សេងៗគ្នា( លិខិត ផ្ទាល់មាត់ )ដែរឬទេ? | | | |
| ៣. | តើព័ត៌មានត្រូវបានផ្តល់ ដោយប្រើប្រាស់ភាសាសាមញ្ញសមស្របដែរឬទេ? | | | |
| ៤. | តើការអញ្ជើញបានផ្តល់ព័ត៌មានអំពីភាពងាយស្រួលចេញចូលកន្លែងប្រជុំដែរឬទេ? | | | |
| ៥. | តើអ្នកចូលរួមដែលជាជនពិការបានសួរនាំអំពីតម្រូវការពាក់ព័ន្ធនឹងការបង្កភាពងាយស្រួលដែរឬទេ? | | | |

**ខ). ការបង្កភាពងាយស្រួលសម្រាប់ជនពិការ ៖ តើឧបសគ្គចំពោះការចូលរួមត្រូវបានលុបបំបាត់ដោយរបៀបណា?**

| ល.រ | ចំណុចដែលត្រូវត្រួតពិនិត្យ | បាទ/ចាស | ទេ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១. | សូមចាំថា ការបង្កភាពងាយស្រួលសម្រាប់ជនពិការ សំដៅលើរចនាសម្ព័ន្ធរូបវន្តផង និងលើវិធីសាស្ត្រប្រាស្រ័យទាក់ទងផង | | | |
| ២. | តើការបង្កភាពងាយស្រួលសម្រាប់ជនពិការគឺសម្រាប់គ្រប់ៗគ្នាឬ? សម្រាប់ក្រុមផ្សេងៗឬ?(ចាស់ជរា ស្ត្រីមានផ្ទៃពោះ និងកុមារ។ល។) | | | |
| ៣. | អត្ថបទរបស់ឯកសារបានប្រើប្រាស់អក្សរដិតច្បាស់ស្របតាមផ្ទៃពណ៌ក្រដាស | | | |

**គ). រៀបចំកន្លែងសម្រាប់កិច្ចប្រជុំ ៖ តើកន្លែងប្រជុំបានបង្កភាពងាយស្រួលសម្រាប់ជនពិការដែរឬទេ?**

| ល.រ | ចំណុចដែលត្រូវត្រួតពិនិត្យ | បាទ/ចាស | ទេ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១. | តើកន្លែងរៀបចំកិច្ចប្រជុំបានពិនិត្យជាមុន ដើម្បីកំណត់ការបង្កភាពងាយស្រួលសម្រាប់ជនពិការដែរឬទេ? | | | |
| ២. | តើអគារប្រជុំមានភាពងាយស្រួលចេញចូលសម្រាប់ជនពិការដែរឬទេ? | | | |
| ៣. | តើបង្គន់ ច្រកផ្លូវដើរ និងកន្លែងញ៉ាំអាហារមានភាពងាយស្រួលប្រើប្រាស់សម្រាប់ជនពិការដែរឬទេ? | | | |

**ឃ). ការធ្វើដំណើរចូលរួមរបស់ជនពិការ ៖ តើជនពិការទៅដល់កន្លែងរៀបចំព្រឹត្តិការណ៍នេះយ៉ាងដូចម្តេច?**

| ល.រ | ចំណុចដែលត្រូវត្រួតពិនិត្យ | បាទ/ចាស | ទេ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១. | តើមានមធ្យោបាយធ្វើដំណើរសាធារណៈ ដែលជនពិការអាចទៅដល់កន្លែងរៀបចំព្រឹត្តិការណ៍ដែរឬទេ? ប្រសិនបើ មិនមាន តើមានជម្រើសផ្សេងទៀតដែរឬទេ?(ឧទាហរណ៍ ៖ ការរៀបចំធ្វើដំណើរដោយមានការគាំទ្រពីអង្គការជនពិការនៅមូលដ្ឋាន)។ | | | |
| ២. | តើមានព័ត៌មានអំពីកន្លែងប្រជុំ និងរបៀបទៅដល់ទីនោះដែរឬទេ? តើមានការគាំទ្រអ្វីខ្លះនៅពេលកិច្ចប្រជុំ? តើមានអ្វីខ្លះដែលត្រូវទូទាត់សងទៅលើការចំណាយ? | | | |
| ៣. | តើមានអ្នកចាំនៅច្រកចូលទៅកន្លែងរៀបចំព្រឹត្តិការណ៍ ដើម្បីនាំផ្លូវទៅកន្លែងដែលពួកគេចាំបាច់ត្រូវ ទៅនិងផ្តល់ជំនួយក្នុងករណីដែលចាំបាច់ដែរឬទេ? | | | |

**ង). ការចូលរួមរបស់ជនពិការ ៖** តើជនពិការអាចចូលរួមនៅក្នុងព្រឹត្តិការណ៍តាមរបៀបណាខ្លះ ?

| លរ | ចំណុចដែលត្រូវត្រួតពិនិត្យ | បាន/មាន | ទេ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១. | តើអ្នកមានព័ត៌មានអំពីអ្នកដែលត្រូវបានអញ្ជើញ ថា តើពួកគេមានតម្រូវការពិសេសអ្វីខ្លះ ចំពោះការបង្កភាពងាយស្រួលសម្រាប់ជនពិការ ឬតើពួកគេនឹងនាំជំនួយការផ្ទាល់ខ្លួនទៅដែរឬទេ ? | | | |
| ២. | ករណី ដែលមានអ្នកខ្សោយខាងស្តាប់មកចូលរួម តើមានការរៀបចំ និងគ្រោងថវិកាសម្រាប់ការបកប្រែសញ្ញាដែរឬទេ ? | | | |
| ៣. | ករណីដែលមានអ្នកខ្សោយគំហើញមកចូលរួម តើមានការរៀបចំ និងគ្រោងថវិកាសម្រាប់រៀបចំព័ត៌មានជាអក្សរស្ទាប អក្សរបោះពុម្ពធំៗ ឬសំឡេងដែរឬទេ ? | | | |
| ៤. | តើវាគ្មិននៅក្នុងកិច្ចប្រជុំនេះ បានទទួលព័ត៌មានអំពីការប្រាស្រ័យទាក់ទងដែរឬទេ ? តើវាគ្មិននិយាយយឺតៗ និងច្បាស់លាស់ដែរឬទេ និងតើមានអ្នកបកប្រែសម្រាប់ជួយបកប្រែដែរឬទេ ? | | | |
| ៥. | តើបន្ទប់ប្រជុំត្រូវបានរៀបចំឡើង ដើម្បីឱ្យរទេះរុញអាចឆ្លងកាត់បានដែរឬទេ ? តើពុំមានវត្ថុអ្វីដែលពួកគេអាចជំពប់ដែរឬទេ ? | | | |
| ៦. | តើកាលវិភាគសមស្របសម្រាប់អ្នកចូលរួមទាំងអស់ដែរឬទេ ? | | | |

## កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

.....................................................................................................................................។

## សង្ខេបមេរៀនជំពូកទី៦

- ប្រសិនបើ គេមិនពិចារណាពីជនពិការនោះទេ នោះពួកគេនឹងពុំមានឱកាសចូលរួមឡើយ។
- ការចូលរួមមានន័យថាជាការចូលរួមនៅក្នុងក្រុមធំមានវត្តមាន និងរួមចំណែកផ្តល់ជាយោបល់។
- អ្នកដែលមានពិការភាពផ្សេងៗគ្នា ជួបប្រទះនឹងឧបសគ្គខុសៗគ្នាដែលរារាំងពួកគេមិនឱ្យចូលរួមបាន
- ប្រសិនបើមានឧបសគ្គ ក៏មានដំណោះស្រាយដែរ។
- "ពុំមានអ្វីសម្រាប់យើងឡើយ ប្រសិនបើពុំមានការចូលរួមពីយើង" មានន័យថាជនពិការគួរចូលរួមនៅក្នុងគ្រប់សកម្មភាពទាំងអស់ដែល មានផលប៉ះពាល់លើពួកគេ។
- គេចាំបាច់ត្រូវធ្វើសកម្មភាពជាក់ស្តែង ដើម្បីឱ្យកិច្ចប្រជុំនានាមានការចូលរួមពីជនពិការ។

# ជំពូកទី៧
# ការដាក់បញ្ចូលពិការភាព
# នៅក្នុងដំណើរការកសាងផែនការ

# ជំពូកទី៧
# ការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការកសាងផែនការ

## ៧.១. វិភាគលើកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌដែលមានស្រាប់

ជនពិការ គឺជាផ្នែកមួយនៃសហគមន៍របស់យើង។ រាល់គម្រោងទាំងអស់ ដែលពាក់ព័ន្ធប្រជាពលរដ្ឋក្នុងសហគមន៍របស់យើង ក៏មានការពាក់ព័ន្ធនឹងជនពិការផងដែរ។ ដូច្នេះ សម្រាប់គម្រោងទាំងអស់ចាំបាច់ត្រូវចាត់ទុកជនពិការជាអ្នកដែលអាចចូលរួមចំណែកនៅក្នុងគម្រោងទាំងនោះ។ យើងមិនអាចផាត់ជនពិការចេញនោះទេ ដោយសារតែជនពិការជាផ្នែកមួយនៃសហគមន៍របស់យើងដែរ។

ពេលខ្លះ ជនពិការមិនបានចូលរួមចំណែកក្នុងគម្រោង ដោយសារតែមានឧបសគ្គជាច្រើន ដែលរារាំងពួកគេមិនឱ្យចូលរួម។ ឧបសគ្គទាំងនេះ បានរារាំងពួកគេមិនឱ្យចូលរួម ទោះបីជាពួកគេចង់ចូលរួមក្នុងគម្រោង ឬគម្រោងនោះមានសារៈសំខាន់ចំពោះពួកគេក៏ដោយ។ ខាងក្រោមជាដំណើរការវិភាគសម្រាប់ការដាក់បញ្ចូលពិការភាពទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលមានស្រាប់ ៖

### ជំហានទី១ ៖ វិភាគលើគម្រោងដែលចាត់ទុកថាពាក់ព័ន្ធឬឆ្លើយតបនឹងជនពិការ

- កំណត់ពីបញ្ជីគម្រោងវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ ដែលគម្រោងវិនិយោគកំពុងអនុវត្តឬកំពុងដំណើរការ (តារាង២.២)

**តារាង ២.២. គម្រោងសម្ពទាពកំពុងដំណើរការ**

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំងគម្រោង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃគម្រោង | ប្រភពមូលនិធិ | កម្រិតទុនវិនិយោគ(លានរៀល) | | | | អង្គភាពអនុវត្ត | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | ២.. | ២.. | ២.. | សរុប | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និង ការបន្សុំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |

- កំណត់ឈ្មោះគម្រោងណាដែលពាក់ព័ន្ធ ឬឆ្លើយតបនឹងជនពិការ ដោយឆ្លើយទៅនឹងសំណួរដូចខាងក្រោម ៖
  - ➢ តើគម្រោងណាខ្លះក្នុងចំណោមគម្រោងទាំងនោះដែលពាក់ព័ន្ធឬឆ្លើយតបជាមួយនឹងជនពិការ?
  - ➢ ហេតុអ្វីបានជាគម្រោងទាំងនោះពាក់ព័ន្ធឬឆ្លើយតបជាមួយនឹងជនពិការ?
  - ➢ តើគម្រោងទាំងនោះផ្តល់ផលប្រយោជន៍សម្រាប់ជនពិការទាំងអស់ ឬក៏សម្រាប់តែជនពិការតាមប្រភេទជាក់លាក់?
  - ➢ តើមានការពិគ្រោះយោបល់ជាមួយជនពិការដែរឬទេ នៅក្នុងអំឡុងពេលកំណត់ពីតម្រូវការ ឬ បញ្ហារបស់ពួកគេ?
  - ➢ តើមានជនពិការប៉ុន្មាននាក់ ដែលបានចូលរួមក្នុងសកម្មភាពគម្រោង?
  - ➢ តើជនពិការគិតយ៉ាងដូចម្តេចអំពីគម្រោងនេះ? តើពួកគេចូលចិត្តគម្រោងនេះដែរឬទេ? តើធ្វើដូចម្តេច ដើម្បីដឹងថាពួកគេចូលចិត្ត ឬមិនចូលចិត្តគម្រោងនេះ?

**ជំហានទី២ ៖ វិភាគលើគម្រោងដែលចាត់ទុកថាមិនពាក់ព័ន្ធឬមិនឆ្លើយតបនឹងជនពិការ**

- ត្រួតពិនិត្យបញ្ជីគម្រោងវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ ដែលគម្រោងវិនិយោគកំពុងអនុវត្ត ឬកំពុងដំណើរការ(តារាង២.២)ឡើងវិញ
- កំណត់ឈ្មោះគម្រោងណាដែលចាត់ទុកថាមិនពាក់ព័ន្ធឬមិនឆ្លើយតបនឹងជនពិការ ឬគម្រោងដែលនៅសល់ពីជំហានទី១
- វិភាគលើគម្រោងទាំងនោះ ដោយឆ្លើយទៅនឹងសំណួរដូចខាងក្រោម ៖
  - ➢ តើគម្រោងទាំងនោះពុំបានផ្តល់ប្រយោជន៍ដល់ជនពិការទេឬ? តើធ្វើដូចម្តេចដើម្បីដឹងថាគម្រោងពុំបានផ្តល់ប្រយោជន៍ដល់ជនពិការ?
  - ➢ តើជនពិការអាចចូលរួម ឬក៏ទទួលផលប្រយោជន៍ពីគម្រោងទាំងនោះបានដែរឬទេ?
  - ➢ តើគម្រោងទាំងនោះ ផ្តល់ផលប្រយោជន៍សម្រាប់ជនពិការទាំងអស់ ឬក៏សម្រាប់តែជនពិការតាមប្រភេទជាក់លាក់?
- វិភាគគម្រោងទាំងនោះដើម្បីដកឧបសគ្គចេញពីជនពិការ ដោយប្រើតារាងវិភាគគម្រោងដូចខាងក្រោម ៖

**ខាងក្រោមជាតារាងវិភាគគម្រោង ដើម្បីដកឧបសគ្គចេញពីជនពិការ ៖**

**គម្រោង ÷** ..........................................................................................

| **ប្រភេទ** | **ឧបសគ្គ** | **ដំណោះស្រាយ** | **អ្នកចាត់វិធានការ** | **ចំណាយ**<br>( ខ្ពស់ មធ្យម ទាប ) |
|---|---|---|---|---|
| ភាពងាយស្រួលក្នុងការចេញចូល | | | | |
| ឥរិយាបថ | | | | |
| ការប្រាស្រ័យទាក់ទង | | | | |
| ការចូលរួម | | | | |

- សូមមើលឧទាហរណ៍ក្នុងតារាងខាងក្រោម ៖

| **គម្រោង ៖ សាលាបឋមសិក្សាថ្មី** | | | | |
|---|---|---|---|---|
| **ប្រភេទ** | **ឧបសគ្គ** | **ដំណោះស្រាយ** | **អ្នកទទួលខុសត្រូវ** | **ចំណាយ** (ខ្ពស់ មធ្យម ទាប) |
| ការបង្កភាពងាយស្រួល និងលទ្ធភាពទទួលបាន | សាលារៀនមិនមានភាពងាយស្រួលសម្រាប់អ្នកប្រើរទេះរុញ | ត្រួតពិនិត្យលើភាពងាយស្រួល និងសង់ជម្រាល និងបង្គន់ដែលងាយស្រួលក្នុងការប្រើប្រាស់ | មេឃុំ រួមជាមួយការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ | មធ្យម |
| ឥរិយាបថ | កុមារពិការទទួលរងការសម្លុតឬធ្វើបាបដោយក្មេងផ្សេងទៀតនៅសាលារៀន | លើកកម្ពស់ការយល់ដឹង អំពី ពិការភាពដល់គ្រូ និងសិស្សនៅសាលារៀន | នាយកសាលា និងអង្គការជនពិការនៅមូលដ្ឋាន | ទាប |
| ការប្រាស្រ័យទាក់ទង | គ្រូបង្រៀនមិនដឹងពីរបៀបបង្រៀនកុមារដែលខ្សោយគំហើញ | បណ្តុះបណ្តាលគ្រូនូវជំនាញ ក្នុងការបង្រៀនកុមារពិការ | អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្របសម្រួលជាមួយការិយាល័យអប់រំ និងអង្គការមិនមែនរដ្ឋាភិបាល | ទាប |
| ការចូលរួម | មិនដឹងពីចំនួនកុមារពិការ ដែលនាំឱ្យគេមិនអាចវាយតម្លៃ ថាតើមានកុមារប៉ុន្មាននាក់ដែល គួរចុះឈ្មោះចូលរៀនក្នុងសាលារៀន | រាប់ចំនួនកុមារពិការ និងអាយុរបស់ពួកគេ | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) | ទាប |

**កំណត់សម្គាល់ ៖**

- លទ្ធផលនៃការវិភាគសម្រាប់ផ្តល់អនុសាសន៍ដល់ក្រុមការងារកសាងផែនការ និងរៀបចំគម្រោង
- រាល់គម្រោងទាំងអស់ដែលពាក់ព័ន្ធជាមួយនឹងមនុស្សនៅក្នុងសហគមន៍របស់យើង ក៏ពាក់ព័ន្ធជាមួយជនពិការផងដែរ។ ដូច្នេះ គ្រប់គម្រោងទាំងអស់ ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីក្រុង ស្រុក ខណ្ឌ ត្រូវទទួលខុសត្រូវក្នុងការធានាឱ្យជនពិការបានចូលរួម និងទទួលផលប្រយោជន៍ពីគម្រោងទាំងនោះ។

## ៧.២. សកម្មភាពជាក់លាក់សម្រាប់ការដាក់បញ្ចូលពិការភាព

**ជំហានទី១ ៖ ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ**

- រៀបចំផែនការសម្រាប់គម្រោងកសាងសមត្ថភាពអំពីការដាក់បញ្ចូលពិការភាពនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ជាពិសេសក្រុមការងារកសាងផែនការ(តាមរយៈការលើកកម្ពស់ការយល់ដឹង)
- ចែករំលែកទិន្នន័យអំពីជនពិការនៅក្នុងក្រុង ស្រុក ខណ្ឌ នៅក្នុងកិច្ចប្រជុំណែនាំដើម្បីកំណត់ និងរៀបចំសំណើគម្រោងវិនិយោគ
- អញ្ជើញតំណាងជនពិការចូលរួមប្រជុំស្តីពីការប្រមូលតម្រូវការអាទិភាព និងប្រជុំបូកសរុប បញ្ជីគម្រោងអាទិភាព
- អញ្ជើញស្ថាប័នដែលធ្វើការផ្នែកពិការភាព ឬធ្វើការជាមួយជនពិការ ឱ្យចូលរួមនៅក្នុងកិច្ចប្រជុំណែនាំ និងចែករំលែកបញ្ហានានាទាក់ទងនឹងជនពិការ
- ធានាថា ទីតាំងសម្រាប់កិច្ចប្រជុំ មានការបង្កភាពងាយស្រួលសម្រាប់ជនពិការ។

**ជំហានទី២ ៖ ការរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ**

- ធានាថា អគារសាធារណៈ និងសម្ភាររូបវន្តដែលមានស្រាប់ និងថ្មីៗ មានការបង្កភាពងាយស្រួលសម្រាប់ជនពិការ
- ធានាថាព័ត៌មានសាធារណៈ (ឧទាហរណ៍ ៖ សុខភាព កសិកម្ម ។ល។) អាចទទួលបាន និងអាចយល់ដឹងបានដោយជនពិការទៅតាមប្រភេទនៃពិការភាព
- រៀបចំសូចនាករដែលមានការដាក់បញ្ចូលពិការភាពនៅក្នុងគម្រោង ឧទាហរណ៍ ចំនួនជនពិការចូលរួមក្នុងការផ្តល់យោបល់ និងចំនួនជនពិការទទួលផលប្រយោជន៍ពីគម្រោង។ល។
- ធានាឱ្យមានការវិភាជន៍ថវិកាសម្រាប់ការបង្កភាពងាយស្រួលដល់ជនពិការ ដូចជា ជួលអ្នកបកប្រែភាសាសញ្ញា ឬការបង្កភាពងាយស្រួលដល់ការធ្វើដំណើរនៃជនពិការកាយសម្បទា..
- ផ្តល់អាទិភាពដល់ក្រុមដែលទន់ខ្សោយជាងគេ ឬជាងគេបំផុត(ដូចជា ស្ត្រីពិការ)
- អញ្ជើញតំណាងអង្គការជនពិការឱ្យចូលរួមនៅក្នុងសិក្ខាសាលា
- ធ្វើឱ្យអង្គការមិនមែនរដ្ឋាភិបាល យល់ដឹង ចាប់អារម្មណ៍អំពីការដាក់បញ្ចូលពិការភាព
- ដាក់បញ្ចូលគម្រោង ឬសូចនាករដែលពាក់ព័ន្ធផ្ទាល់ទៅនឹងពិការភាពក្នុងក្របខ័ណ្ឌ (តារាង) និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិ តាមដានលក្រុង ស្រុក ខណ្ឌ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការដាក់បញ្ចូលពិការភាពក្នុងគម្រោងផ្អែកទៅតាមសូចនាករ និងការវាស់វែងលើផលប៉ះពាល់របស់គម្រោងទៅលើជនពិការ
- មានតំណាងជនពិការនៅក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

**ជំហានទី៧ ៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ**

- មានតំណាងជនពិការចូលរួមកិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌ
- ធ្វើឱ្យក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ យល់ដឹង ចាប់អារម្មណ៍អំពីការដាក់បញ្ចូលពិការភាព
- អភិបាលក្រុង ស្រុក ខណ្ឌ ឬ ក្រុមការងារកសាងផែនការ គប្បីណែនាំឱ្យមានការផ្សព្វផ្សាយ ខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធ ជាពិសេសជនពិការ តាមរយៈកិច្ចប្រជុំនានា វេទិកាសាធារណៈ សារព័ត៌មាន វិទ្យុ និងមធ្យោបាយផ្សេងៗទៀត។

## សង្ខេបមេរៀនជំពូកទី៧

- គម្រោងដែលមានស្រាប់នៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ**បីឆ្នាំរំកិល**ក្រុង ស្រុក ខណ្ឌ មិនមែនសុទ្ធតែបញ្ចូលជនពិការនោះទេ។
- ដើម្បីឱ្យគម្រោងមួយមានការដាក់បញ្ចូលពិការភាព គេចាំបាច់ត្រូវតែដឹងពីឧបសគ្គ និងលុបបំបាត់ឧបសគ្គទាំងនេះ។
- ដំណោះស្រាយជាច្រើនមិនចំណាយថវិកាច្រើនពេកនោះទេ ប៉ុន្តែត្រូវការវិនិយោគពេលវេលា និងត្រូវមានភាពច្បាស់លាស់ពីអ្នកដែលត្រូវចាត់វិធានការ។
- ការដោះស្រាយឧបសគ្គចម្បងៗបានពេលវេលានៅក្នុង**ដំណើរការរៀបចំ និង**កសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ**បីឆ្នាំរំកិល**ក្រុង ស្រុក ខណ្ឌ រឹតតែបង្កើនការចូលរួមខ្លាំងក្លាពីជនពិការ។ ដោះស្រាយកាន់តែឆាប់កាន់តែប្រសើរ។
- ការដាក់បញ្ចូលជនពិការ អាចធ្វើឡើងនៅគ្រប់ដំហានទាំងអស់នៅក្នុង**ដំណើរការ រៀបចំ និង**កសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ**បីឆ្នាំរំកិល**ក្រុង ស្រុក ខណ្ឌ និងគ្រប់គម្រោងទាំងអស់របស់ក្រុង ស្រុក ខណ្ឌ។



## កំណត់សម្គាល់ផ្ទាល់ខ្លួនសម្រាប់មេរៀន

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

............................................................................................................................................

..............................................................................................................................។

# ជំពូកទី៨

# ការវាយតម្លៃវគ្គបណ្តុះបណ្តាល
# និងបញ្ជីអង្គការសង្គមស៊ីវិល
# ដែលធ្វើការខារពិការភាព

# ជំពូកទី៨
# ការវាយតម្លៃវគ្គបណ្តុះបណ្តាល និងបញ្ជីអង្គការសង្គមស៊ីវិលដែលធ្វើការងារពិការភាព

## ៨.១. ការវាយតម្លៃវគ្គបណ្តុះបណ្តាល

តើមានសកម្មភាពអ្វីខ្លះដែលត្រូវអនុវត្តបន្ទាប់ពីទទួលបានវគ្គបណ្តុះបណ្តាល?

..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
.............................................................................................................................................។

តើបានចងចាំចំណុចសំខាន់ៗអ្វីខ្លះពីវគ្គបណ្តុះបណ្តាលនេះ?

..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
.............................................................................................................................................។

## ៨.២. អង្គការដែលធ្វើការងារជាមួយ ឬផ្តល់សេវាដល់ជនពិការ

ខាងក្រោមនេះ គឺជាបញ្ជីឈ្មោះអង្គការដែលធ្វើការងារជាមួយ ឬផ្តល់សេវាដល់ជនពិការ។ នេះមិនមែនជាបញ្ជីរាយឈ្មោះគ្រប់អង្គការនោះទេ។ សម្រាប់ព័ត៌មានបន្ថែម អ្នកអាចទំនាក់ទំនងទៅកាន់អង្គការទាំងនេះ ហើយអង្គការទាំងនេះប្រហែលជាអាចជួយអ្នកក្នុងការទំនាក់ទំនងជាមួយអង្គការដែលអ្នកត្រូវការ។

**អង្គការ អេឌីឌីអន្តរជាតិកម្ពុជា** ( ADD International Cambodia )

ក្រុមគោលដៅ ៖ អង្គការជនពិការ
តំបន់គោលដៅ ៖ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ ព្រៃវែង សៀមរាប កំពង់ធំ ស្វាយរៀង តាកែវ កណ្តាល កំពង់ចាម កំពត
អាសយដ្ឋាន ៖ ផ្ទះលេខ៧៤ ផ្លូវលេខ៥៨៤ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៨៨៥ ០០៦

**អង្គការ ត្រចៀកកម្ពុជា** ( All Ears Cambodia )

ក្រុមគោលដៅ ៖ ជនពិការថ្លង់ និងអ្នកដែលពិបាកស្តាប់
តំបន់គោលដៅ ៖ ភ្នំពេញ និង ទទួលពីខេត្ត ក្រុង ក្នុងប្រទេសកម្ពុជា
អាសយដ្ឋាន ៖ ផ្ទះលេខ ១០៩ z ផ្លូវលេខ ២២៨ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១១ ៧៧៥ ០៦៣

**សមាគមនៃជនពិការភ្នែក កម្ពុជា** ( Association of the Blind in Cambodia - ABC )

ក្រុមគោលដៅ ៖ ជនពិការភ្នែក និងអ្នកខ្សោយគំហើញ
តំបន់គោលដៅ ៖ ភ្នំពេញ កំពង់ស្ពឺ កំពង់ចាម ក្រុងព្រះសីហនុ
អាសយដ្ឋាន ៖ ផ្ទះលេខ១១F ផ្លូវលេខ៦០C សង្កាត់ស្ទឹងមានជយ័ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៦១៨ ៨៨២

**អង្គការ ជនពិការកម្ពុជា** ( CDPO )

ក្រុមគោលដៅ ៖ ជនពិការគ្រប់ប្រភេទ
តំបន់គោលដៅ ៖ ទូទាំងប្រទេសកម្ពុជា
អាសយដ្ឋាន ៖ វត្តថាន់ មហាវិថីព្រះនរោត្តម ទន្លេបាសាក់ ចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ២២១ ៨២៣/០១២ ៨៥១ ៨៤១

**អង្គការ កម្ពុជាត្រាស់/អិចស៊ីដ** (Cambodia Trust/Exceed)

ក្រុមគោលដៅ ៖ ឧបករណ៍រណប និងអវៈយវៈសប្បនិម្មិត
តំបន់គោលដៅ ៖ ភ្នំពេញ ព្រះសីហនុ (កំពង់សោម) និងកំពង់ឆ្នាំង
អាសយដ្ឋាន ៖ ផ្ទះលេខ ២០សេ ក្រុមទី៣ ផ្លូវដូងងៀប សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ៨៨១ ៤៩៤/០២៣ ៨៦៤ ០៤៦

**អង្គការ អភិវឌ្ឍន៍សមត្ថភាពដើម្បីសហប្រតិបត្តិការជនពិការ** (CABDICO)

ក្រុមគោលដៅ ៖ ជនពិការ ការព្យាបាលអ្នកដែលមានបញ្ហាខាងនិយាយ
តំបន់គោលដៅ ៖ សៀមរាប កែប
អាសយដ្ឋាន ៖ កុដលេខ ៤៣ (ក្នុងវត្តសារាវន្ត) ផ្លូវលេខ ១៧៨ (ជិតកែងផ្លូវនរោត្តម) ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១៧ ៤៥៤ និង ០១២ ៨៨៣ ៦៤៧

**កម្មវិធីអភិវឌ្ឍន៍មនុស្សថ្លង់** (DDP)

ក្រុមគោលដៅ ៖ ជនពិការថ្លង់ អ្នកពិបាកស្តាប់
តំបន់គោលដៅ ៖ កំពង់ចាម ភ្នំពេញ កំពត
អាសយដ្ឋាន ៖ ផ្ទះលេខ៧ អា ផ្លូវលេខ ១០១ បឹងត្របែក រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ៩៨៧ ៩៣១ និង ០១៧ ៩៩៣ ៣២១ និង ០១២ ៧៦៣ ៧៧៦

**អង្គការ សេវាអភិវឌ្ឍន៍ជនពិការ ខេត្តពោធិ៍សាត់**

ក្រុមគោលដៅ ៖ កុមារ និង មនុស្សចាស់ពិការ
តំបន់គោលដៅ ៖ ពោធិ៍សាត់ និង ខេត្តប៉ៃលិន
អាសយដ្ឋាន ៖ ភូមិពាលញែក ២ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
ទូរស័ព្ទ ៖ ០៩២ ២៦៦ ៤៩៣ និង ០៥២ ៩៥១៤៩៥

**មូលនិធិ ហ្វ្រេតហូលូកម្ពុជា** Fred Hollows Foundation

ក្រុមគោលដៅ ៖ សុខភាពភ្នែកទូទៅ លើកកម្ពស់យេនឌ័រ និងជនពិការឲ្យបានទទួលសេវាភ្នែក
តំបន់គោលដៅ ៖ រាជធានីភ្នំពេញ មន្ទីរពេទ្យខ្មែរ សូវៀត មន្ទីរពេទ្យអង្គឌួង មន្ទីរពេទ្យក្រុងភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ សៀមរាប ឧត្តរមានជ័យ ប៉ៃលិន ព្រះវិហារ ព្រះសីហនុ ព្រៃវែង
អាសយដ្ឋាន ៖ ប្រអប់សំបុត្រ ៥១៨ បន្ទប់២០១ ការិយាល័យ ១៦០ ផ្លូវលេខ៧១ ទន្លេបាសាក់ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ (៨៥៥)២៣ ៩៨៧ ៨៣១

**អង្គការ មូលនិធិកុមារពិការ**

ក្រុមគោលដៅ ៖ កុមារ និងយុវជនពិការ កម្រិតមធ្យមនិងធ្ងន់ធ្ងរ (រាងកាយ និងសតិបញ្ញា)
តំបន់គោលដៅ ៖ ភ្នំពេញ កំពត ក្រចេះ
អាសយដ្ឋាន ៖ កុដលេខ ៤៣ (ក្នុងវត្តសារាវ័ន្ត) ផ្លូវលេខ ១៧៨ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១០ ៤៤៧ និង ០១២ ៨៤៣ ៤៦៦

**អង្គការ គ្រួសារថ្មី**

ក្រុមគោលដៅ ៖ ជនពិការភ្នែក និងខ្សោយគំហើញ, ជនពិការថ្លង់ និងខ្សោយខាងការស្តាប់
តំបន់គោលដៅ ៖ ១៤ រាជធានី ខេត្តក្នុងប្រទេសកម្ពុជា និងជាពិសេស រាជធានីភ្នំពេញ ខេត្តកំពង់ចាម សៀមរាប បាត់ដំបង សិរីសោភ័ណ កំពង់សោម
អាសយដ្ឋាន ៖ ផ្ទះលេខ ៤ ផ្លូវលេខ ២៥៧ ទឹកល្អក់ ១ ទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ៨៨០ ៥០៣

**អង្គការ មនុស្សលោកថ្មី**

ក្រុមគោលដៅ ៖ ជនពិការ
តំបន់គោលដៅ ៖ ខេត្តកំពង់ឆ្នាំង
អាសយដ្ឋាន ៖ ប្រអប់សំបុត្រលេខ ៤៨ ផ្ទះលេខ ១៩ ផ្លូវលេខ ៣១៧ បឹងកក់ ១ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ២២០ ២៦៣

**អង្គការ សប្បុរសធម៌ Rose Charity**

ក្រុមគោលដៅ ៖ ព្យាបាលភ្នែក
តំបន់គោលដៅ ៖ រាជធានីភ្នំពេញ
អាសយដ្ឋាន ៖ កន្លែងវះកាត់ មន្ទីរពេទ្យបង្អែកជ័យជំនះ ផ្លូវជាតិលេខ ២ ក្រុងតាខ្មៅ ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១២ ៩៤០ ៣១២/០២៤ ៩៨៥ ៧៦៧

**អង្គការ ចិត្តសង្គមអន្តរវប្បធម៌ (TPO) កម្ពុជា**

ក្រុមគោលដៅ ៖ សុខភាពផ្លូវចិត្ត និងស្តារលទ្ធភាពចិត្តសង្គម
តំបន់គោលដៅ ៖ រាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប កំពង់ធំ ត្បូងឃ្មុំ កំពង់ចាម កណ្តាល កំពង់ឆ្នាំង
អាសយដ្ឋាន ៖ ផ្ទះលេខ២-៤ ផ្លូវលេខ១៩៥២ សង្កាត់ភ្នំពេញថ្មី រាជខណ្ឌសែនសុខ ធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ៦៣៦ ៦៩៩២

## អង្គការ អតីតយុទ្ធជនអន្តរជាតិកម្ពុជា

ក្រុមគោលដៅ ៖ ស្តារលទ្ធភាពកាយសម្បទា

តំបន់គោលដៅ ៖ រាជធានីភ្នំពេញ ខេត្តកណ្តាល ក្រចេះ ព្រៃវែង និងស្វាយរៀង

អាសយដ្ឋាន ៖ ផ្លូវជាតិ ៦អា ភូមិកៀនឃ្លាំង សង្កាត់ជ្រោយចង្វារ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ៤៣០ ៩៤២/ ០១១ ៧២៨ ៧០២

## អង្គការជនពិការអន្តរជាតិ

ក្រុមគោលដៅ ៖ ជនពិការកាយសម្បទា (ផ្តល់អវៈយវៈសិប្បនិម្មិត រណបនិង ឧបករណ៍ជំនួយចលត័ភាព

តំបន់គោលដៅ ៖ រាជធានីភ្នំពេញ សៀមរាប កំពង់ចាម

អាសយដ្ឋាន ៖ ផ្ទះលេខ ៩AB ផ្លូវលេខ៤៤៦ សង្កាត់ទួលទំពូងI ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១២ ៨៩៧/(៨៥៥) ២៣ ២១៧ ៣០០